NGO-CEDAW

# របាយការណ៍ស្តីពីការត្រួតពិនិត្យលើការអនុវត្តអនុសញ្ញាស៊ី-ដសម្រាប់ប្រទេសកម្ពុជា

## ប្រចាំឆ្នាំ២០២១



NagaWorld workers strike on December 24, 2021. Picture: CCHR

ការិយាល័យ NGO- CEDAW
ផ្ទះលេខ ១៦ ផ្លូវ ៩៩ សង្កាត់បឹងត្របែក ខណ្ឌចំការមន ក្រុងភ្នំពេញ
ngocedaw.pnh@gmail.com
https://ngocedaw.org

# មាតិកា


សេចក្តីសង្ខេបនៃឆ្នាំ២០២១....2

សិទ្ធិសេរីភាពជាមូលដ្ឋាន....3

១) សេរីភាពនៃការប្រមូលផ្តុំ....4

២) សេរីភាពនៃការបញ្ចេញមតិ....5

៣) សេរីភាពនៃការបង្ហាញភាពជាខ្លួនឯង....5

ស្ត្រីនៅក្នុងពន្ធនាគារ....7

អំពើហិង្សាផ្អែកលើយេនឌ័រ....8

១) ស្ថិតិអំពីអំពើហិង្សាផ្អែកលើយេនឌ័រសម្រាប់ឆ្នាំ២០២១....8

២) ស្រមោលនៃការរីករាលដាលនៃអំពើហិង្សាផ្អែកលើយេនឌ័រនៅក្នុងបរិបទនៃមេរោគកូវីដ១៩....9

៣) អំពើជួញដូរមនុស្ស....10

៤) អំពើបៀតបៀនតាមប្រព័ន្ធអនឡាញទៅលើស្ត្រី កុមារី និងបុគ្គលមិនកំណត់អត្តសញ្ញាណយេនឌ័រណាមួយ....10

៥) ការប្រើប្រាស់មិនត្រឹមត្រូវនូវការដោះស្រាយជម្លោះតាមវិធីសាស្ត្រផ្សេងៗក្នុងករណីអំពើហិង្សាផ្អែកលើយេនឌ័រ....12

៦) ភាពជាអាជ្ញាកណ្តាលនៅក្នុងការអនុវត្តច្បាប់ក្នុងករណីអំពើហិង្សាផ្អែកលើយេនឌ័រ....14

ការងារ....16

១) ការរើសអើងក្នុងវិស័យសារពត៌មាន....16

២) ការរើសអើងលើអ្នកធ្វើការនៅក្នុងសេវាកំសាន្ត....17

៣) ការបៀតបៀនផ្លូវភេទ....18

សុខភាព....19

ការរើសអើងលើសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា ជាពិសេសការទទួលការថែទាំសុខភាព និងការងារ....21

អនុសាសន៍របស់សង្គមស៊ីវិល ដើម្បីអនុវត្តកាន់តែប្រសើរនូវសេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការទទួលបន្ទុកលើអនុសញ្ញាស៊ីដ....22

ការវិវឌ្ឍន៍នៃការអនុវត្តនូវសេចក្តីសង្កេតសន្និដ្ឋានអនុសញ្ញាស៊ីដ ឆ្នាំ២០១៩....24

## សេចក្តីសង្ខេបនៃឆ្នាំ២០២១

ព្រឹត្តិការណ៍ដែលលេចធ្លោជាងគេនៃឆ្នាំ២០២១នេះ គឺការឆ្លងរីករាលដាលមេរោគកូវីដ ១៩នៅក្នុងសហគមន៍ ដែលនាំឱ្យមានការរឹតបន្តឹងថ្មីៗ រួមមានបំរាមគោចរណ៍ និងការបិទខ្ទប់ ភាពតានតឹងនៅក្នុងមន្ទីរពេទ្យ និងចំនួនអ្នកស្លាប់ ដែលបណ្តាលអោយប៉ះពាល់ដោយមិនមានលក្ខណៈសមាមាត្រទៅលើស្ត្រីមានផ្ទៃពោះដែលមិនបានចាក់វ៉ាក់សាំង ។ ការរឹតបន្តឹងដែលកំពុងអនុវត្ត មានការកំហិតលើការធ្វើដំណើរ ការបិទសាលារៀន និងអាជីវកម្មជាច្រើនបានបន្តផ្តល់ផលប៉ះពាល់មិនល្អលើផ្លូវចិត្ត ការសិក្សាអប់រំ និងផ្នែកសេដ្ឋកិច្ចលើកុមារី និងស្ត្រីកម្ពុជា។ ការផ្តល់ថវិកាជំនួយរបស់រដ្ឋាភិបាលដល់អាជ្ញាធរមូលដ្ឋាន ត្រូវបានកើនឡើងដើម្បីជួយគាំទ្រដល់វិធានការប្រឆាំងនិងមេរោគកូវីដ ១៩ ប៉ុន្តែបានបង្វែរចេញនូវការផ្តល់សេវាដោយផ្ទាល់សម្រាប់សុខភាពស្ត្រី និងអំពើហិង្សាផ្អែកលើយេនឌ័រទៅវិញ។ មានកិច្ចខិតខំប្រឹងប្រែងប្រកបដោយភាពវិជ្ជមានជាច្រើនដែលបានអនុវត្តដោយរាជរដ្ឋាភិបាល ដូចជាកិច្ចប្រឹងប្រែងអនុម័តគោលនយោបាយជាតិស្តីពីសមភាពយេនឌ័រដែលមានការវិវឌ្ឍន៍ខ្លះៗ តែត្រូវបានផ្អាកទៅវិញ។ កិច្ចប្រឹងប្រែងទាំងនេះធ្វើឡើងដើម្បីអនុវត្តផែនការសកម្មភាពជាតិក្នុងគោលបំណងទប់ស្កាត់អំពើហិង្សាលើស្ត្រី (NAPVAW3) និងការតាក់តែងគោលនយោបាយនានាដើម្បីយកទៅបណ្តុះបណ្តាលអាជ្ញាធរ មូលដ្ឋានក្នុងគោលបំណងបញ្ចៀសនូវការប្រើប្រាស់មិនត្រឹមត្រូវនៃការដោះស្រាយជម្លោះតាមវិធីសាស្ត្រផ្សេងៗនៅក្នុងករណីអំពើហិង្សាក្នុងគ្រួសារ។ នៅចុងឆ្នាំ២០២១ ហាក់មានលក្ខណៈអំណោយផលដោយថវិកាជំនួយបន្ថែមទៀតត្រូវប្រកាសផ្តល់ឱ្យពីសំណាក់អង្គការសហប្រជាជាតិទទួលបន្ទុកផ្នែកស្ត្រី (UNWOMEN) និងពីស្ថានទូតរដ្ឋាភិបាលអូស្ត្រាលីសម្រាប់យកទៅអនុវត្តផែនការសកម្មភាពជាតិ ក្នុងគោលបំណងទប់ស្កាត់អំពើហិង្សាលើស្ត្រី និងសម្រាប់ការងារបញ្ជ្រាបយេនឌ័រផ្សេងទៀត។ ក៏ប៉ុន្តែទាំងនេះមិនទាន់បានជួយដោះស្រាយក្តីកង្វល់ចម្បងដែលបានលើកឡើងដោយអង្គការសង្គមស៊ីវិលនៅឡើយទេ គឺថាបើគ្មានការដាក់ចេញនូវថវិកាសម្រាប់អនុវត្តរយៈពេលវែងពីថវិកាជាតិនោះទេ គឺបង្ហាញថាបញ្ហាយេននឌ័រនៅមិនទាន់ត្រូវបានផ្តល់អាទិភាពពិតប្រាកដនៅឡើយ។

បន្ថែមពីលើនេះ សិទ្ធិសេរីភាពជាមូលដ្ឋានជាច្រើនរបស់ស្ត្រីនៅតែមិនទាន់ទទួលបានការពារនៅឡើយ។ ពេញមួយឆ្នាំនេះ ពោរពេញទៅដោយការបង្ក្រាបជាច្រើនដងលើកូដកម្មដោយសន្តិវិធីដែលដឹកនាំដោយស្ត្រី ដើម្បីប្រឆាំងទៅនឹងក្រុមហ៊ុនណាហ្គាវើលដ៍ ដែលក្រុមហ៊ុននេះបានបញ្ឈប់បុគ្គលិកជាច្រើនរបស់ខ្លួននៅក្នុងឆ្នាំ ២០២១ ដោយមានលក្ខណៈវិសមាមាត្រលើស្ត្រីមានផ្ទៃពោះ និងកំពុងបំបៅដោះកូន ព្រមទាំងសមាជិកសហជីពជាស្ត្រីផងដែរ។

របាយការណ៍នេះ ជាសេចក្តីសង្ខេបនៃក្តីកង្វល់ និងព្រឹត្តិការណ៍សំខាន់ៗដែលបានកើតឡើងនៅក្នុងឆ្នាំ២០២១។ របាយការណ៍នេះមិនមានគោលបំណងបង្ហាញនូវរាល់បញ្ហាទាំងអស់ដែលស្ត្រី កុមារី និងបុគ្គលមិនកំណត់នូវអត្តសញ្ញាណយេនឌ័រណាមួយនៅក្នុងប្រទេសកម្ពុជាកំពុងប្រឈមនោះឡើយ ប៉ុន្តែមានគោលបំណងផ្តោតសំខាន់ទៅលើបញ្ហាកើតឡើងថ្មីៗ ជាពិសេសនៅក្នុងឆ្នាំ២០២១។ មានបញ្ហាមួយចំនួនបានកើតឡើងនៅឆ្នាំ២០២២ ប៉ុន្តែមិនត្រូវបានដាក់បញ្ចូលក្នុងរបាយការណ៍នេះទេ។

## សិទ្ធិសេរីភាពជាមូលដ្ឋាន

ទោះបីមានការប្តេជ្ញាចិត្តរបស់កម្ពុជាក្នុងរដ្ឋធម្មនុញ្ញ និងនៅក្នុងកិច្ចប្រជុំរបស់អង្គការសហប្រជាជាតិនាពេលកន្លងមកដើម្បីការពារការអនុវត្តនៃសិទ្ធិសេរីភាពជាមូលដ្ឋានរបស់ស្ត្រី និងកុមារីក៏ដោយ ក៏ការអនុវត្តជាក់ស្តែងរាជរដ្ឋាភិបាលធ្វើការរឹតបន្តឹង និងរំលោភលើសិទ្ធិទាំងនេះជាប្រចាំ ហើយក៏ពុំមាននីតិវិធីច្បាប់ក្នុងស្រុកអាចផ្តល់ដំណោះស្រាយសម្រាប់ការរំលោភបំពានលើសិទ្ធិទាំងនេះដែរ។ ជាក់ស្តែង ច្បាប់ត្រូវបានបកស្រាយ និងប្រើប្រាស់មិនត្រឹមត្រូវដែលបណ្តាលឱ្យមានគំនិតយល់ឃើញផ្សេងៗគ្នា។ រាជរដ្ឋាភិបាលអនុវត្តច្បាប់ដែលមានស្រាប់ដោយមិនស្របតាមគោលបំណងនៃច្បាប់ដែលបានតាក់តែងឡើង ដើម្បីធ្វើការឃុំខ្លួន ចាប់ខ្លួន និងដាក់ទោសព្រហ្មទណ្ឌលើសកម្មភាពភាពដែលអនុវត្តដោយស្ត្រី ដែលកត្តានេះបានរារាំងស្ត្រីពីការអនុវត្តសេរីភាពនៃការបង្ហាញភាពជាខ្លួនឯង និងសេរីភាពជាមូលដ្ឋានផ្សេងទៀតផងដែរ។ ច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ (ច្បាប់ប្រឆាំងការជួញដូរមនុស្ស) និងផ្នែកខ្លះនៃក្រមព្រហ្មទណ្ឌ ត្រូវបានតាក់តែងឡើងដើម្បីបញ្ឈប់អំពើជួញដូរមនុស្ស តែត្រូវបានប្រើប្រឆាំងនឹងស្ត្រីចំពោះការដែលពួកគេជាអ្នកប្រកបរបររកស៊ីផ្លូវភេទ និងការបង្ហាញឬធ្វើសកម្មភាពដែលត្រូវបានចោទថាមានលក្ខណៈស៊ិចស៊ីតាមប្រព័ន្ធអនឡាញ ឬការធ្វើជាអ្នកពរពោះជំនួសទៅវិញ។ ម្យ៉ាងទៀតរាជរដ្ឋាភិបាល បានប្រើច្បាប់ស្តីពីការប្រមូលផ្តុំដោយសន្តិវិធី ក្រមព្រហ្មទណ្ឌ និងច្បាប់នានាស្តីពីមេរោគកូវីដ ១៩ ដែលត្រូវបានអនុម័តថ្មីៗនេះ ធ្វើជាលេសដើម្បីរារាំងមិនឱ្យសកម្មជនសហជីពចូលរួមធ្វើកូដកម្មដោយសន្តិវិធី និងដើម្បីឃុំខ្លួន ចាប់ខ្លួន និងចោទប្រកាន់ផ្លូវច្បាប់លើពួកគេ។ បម្រាមដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញស្តីពីការប្រមាថព្រះមហាក្សត្រ ដែលទើបត្រូវបានធ្វើវិសោធនកម្មថ្មីៗនេះ ត្រូវបានប្រើដើម្បីធ្វើការចោទប្រកាន់ពីបទព្រហ្មទណ្ឌលើ សកម្មជនបរិស្ថានចំពោះការនិយាយដែលមានលក្ខណៈឯកជនរបស់ពួកគេ។

នៅក្នុងឆ្នាំ២០២១ មានមនុស្សយ៉ាងតិច៣៩នាក់ ភាគច្រើនគឺជាស្ត្រី ត្រូវបានចាប់ខ្លួន ឃុំខ្លួន និងស្វែងរកចាប់ខ្លួនពីសំណាក់អាជ្ញាធរចំពោះការធ្វើទំនាក់ទំនងលើប្រព័ន្ធផ្សព្វផ្សាយសង្គម ដែលការនិយាយនេះគួរទទួលបានការការពារក្រោមច្បាប់រដ្ឋធម្មនុញ្ញកម្ពុជា។[1] មិនតែប៉ុណ្ណោះរាជរដ្ឋាភិបាលអាចនឹងប្រឹងប្រែងជាថ្មីដើម្បីអនុម័តសេចក្តីព្រាងច្បាប់ស្តីពីសណ្តាប់ធ្នាប់សាធារណៈនេះ។ ដូចគ្នានេះដែរ នៅក្នុងឆ្នាំ២០២១ ច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ (ច្បាប់ប្រឆាំងការជួញដូរមនុស្ស) ក្នុងបទបញ្ញត្តិស្តីពីរូបភាព និងសម្ភារៈអាសអាភាស ត្រូវបានប្រើប្រឆាំងនឹងស្ត្រីដែលសន្មត់ថា ស្លៀកពាក់ ឬធ្វើសកម្មភាព "ស៊ិចស៊ីហួសហេតុ" នៅលើហ្វេសប៊ុក មិនតែប៉ុណ្ណោះក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ កំពុងពិចារណាបង្កើត "ក្រមប្រតិបត្តិវប្បធម៌" ដើម្បីដាក់កំហិតតឹងរ៉ឹងបន្ថែមទៀតលើការបង្ហាញពីភាពជាខ្លួនឯងរបស់ស្ត្រី។[2] ជាចុងក្រោយ ពុំមានការសិក្សាវាយតម្លៃលើផលប៉ះពាល់យេនឌ័រត្រូវបានធ្វើឡើងមុននឹងគោលនយោបាយ និងច្បាប់ទាំងនេះត្រូវបានធ្វើសេចក្តីព្រៀង ឬអនុ

[1] Cambodian Center for Human Rights (CCHR) monitoring data.
[2] Cambodian Center for Human Rights (CCHR) monitoring data.

## ១) សេរីភាពនៃការប្រមូលផ្តុំ

ទោះជាមានការស្នើសុំរបស់គណៈកម្មាធិការនៃអង្គការសហប្រជាតិ ទទួលបន្ទុកលើអនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រី (គណៈកម្មាធិការស៊ី-ដ) ក៏សង្គមស៊ីវិលពុំទាន់សង្កេតឃើញមានកិច្ចប្រឹងប្រែងណាមួយដោយរាជរដ្ឋាភិបាលក្នុងការកាត់បន្ថយការបៀតបៀន និងការរឹតបន្តឹងដែលកំពុងកើតមានលើការប្រើប្រាស់សិទ្ធិសេរីភាពជាមូលដ្ឋានរបស់សកម្មជនជាស្ត្រីនៅឡើយ។ នៅអំឡុងពេលការរីករាលដាលនៃជំងឺកូវីដ១៩ ការប្រព្រឹត្តទៅលើថ្នាក់ដឹកនាំសហជីពជាស្ត្រីដែលប្រឈមនឹងបញ្ហាស្រាប់ទៅហើយនោះ រឹតតែធ្វើឱ្យស្ថានភាពរបស់ពួកគេកាន់តែមានសភាពធ្ងន់ធ្ងរឡើង កត្តានេះបានបង្ហាញថាមានការលំបាកក្នុងការអនុវត្តសិទ្ធិសេរីភាពនៅក្នុងប្រទេសកម្ពុជា។ ជាក់ស្តែងដូចជា សហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរនៃក្រុមហ៊ុនណាហ្គាវើលដ៍ (LRSU) ដែលមានសមាជិកភាគច្រើនគឺជាស្ត្រី បានប្រឈមនឹងការលំបាកក្នុងការអនុវត្តសិទ្ធិសេរីភាពរបស់ខ្លួន។ កាលពីខែធ្នូ ឆ្នាំ២០២១ សហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរបានចាប់ផ្តើមធ្វើកូដកម្ម និងបាតុកម្ម ជិតកាស៊ីណូណាហ្គាវើលដ៍នៅក្នុងទីក្រុងភ្នំពេញ ក្រោយពីមានគម្រោងកាត់បន្ថយបុគ្គលិកចំនួន១៣២៩ នាក់ ដោយក្រុមហ៊ុនណាហ្គាវើលដ៍ នៅក្នុងឆ្នាំ២០២១។ ការកាត់បន្ថយចំនួនបុគ្គលិកនេះធ្វើឡើង ដោយហេតុផលវិបត្តិនៃជំងឺកូវីដ ១៩ បើទោះបីជាអាជីវកម្មរបស់ក្រុមហ៊ុនបានបង្កើតប្រាក់ចំណេញច្រើនក្នុងឆ្នាំ២០២០ ហើយក្រុមហ៊ុនក៏កំពុងបន្តសាងសង់អគារណាហ្គា៣ ដែលនឹងត្រូវការបុគ្គលិកចំនួន ៩០០០នាក់បន្ថែមទៀត។ ៨២%នៃបុគ្គលិកដែលត្រូវបានបញ្ឈប់ គឺជាសមាជិកសហជីព រួមទាំងថ្នាក់ដឹកនាំសហជីពមូលដ្ឋានទាំងមូល។ ថ្នាក់ដឹកនាំសហជីពក៏សង្កេតឃើញថា ការកាត់បន្ថយបុគ្គលិកនេះសំដៅទៅលើស្ត្រីដែលមានផ្ទៃពោះ ឬស្ត្រីដែលទើបនឹងសម្រាលកូនរួច។ កូដកម្មនាពេលថ្មីៗកន្លងមកនេះធ្វើឡើងដើម្បីទាមទារឱ្យក្រុមហ៊ុនទទួលយកបុគ្គលិកចំនួន ៣៦៥នាក់ឱ្យចូលធ្វើការវិញ។

រាជរដ្ឋាភិបាលហាក់មានទំនោរទៅខាងនយោជកនៅក្នុងជម្លោះការងារនេះ ទន្ទឹមពេលជាមួយគ្នានេះដែរក្រសួងការងារ បានដើរតួនាទីជាអ្នកសម្រុះសម្រួលនៅក្នុងជម្លោះនេះ។ កាលពីខែធ្នូ ឆ្នាំ២០២១ មន្ត្រីរដ្ឋាភិបាលបានបង្ហោះការអះអាងនានានៅក្នុងប្រព័ន្ធផ្សព្វផ្សាយសង្គមថា ស្ត្រីមានផ្ទៃពោះត្រូវបានបង្ខំឱ្យចូលរួមតវ៉ាជាផ្នែកមួយនៃបដិវត្តន៍ពណ៌ ហើយថាបាតុកម្មទាំងនេះត្រូវបានញុះញង់ដោយជនបរទេស ដែលការចោទប្រកាន់បែបនេះធ្វើឱ្យប៉ះពាល់ដល់ទីភ្នាក់ងារ និងសិទ្ធិសេរីភាពជាមូលដ្ឋានរបស់ស្ត្រីកម្ពុជា។ ក្រោយមកនៅក្នុងខែជាមួយគ្នានេះដែរមន្ត្រីរាជរដ្ឋាភិបាលបានចាប់ផ្តើមដំណើរការនៃការចាប់ឃ្លួន ឃុំខ្លួនថ្នាក់ដឹកសហជីពជាស្ត្រី ដោយប្រើប្រាស់មិនត្រឹមត្រូវនូវច្បាប់នានាក្នុងគោលបំណងធ្វើការចោទប្រកាន់ស្ត្រីទាំងនេះពីបទញុះញង់ និងប្រើប្រាស់ ដោយមិនត្រឹមត្រូវចំពោះវិធានការការពារជំងឺកូវីដ ១៩ ច្បាប់ស្តីពីការធ្វើបាតុកម្ម ដើម្បីប្រឆាំងនឹងកូដកម្មដែលដឹកនាំដោយស្ត្រី។ គួរឱ្យកត់សម្គាល់ផងដែរថា នៅពេលដែលមានការផ្ទុះការរីករាលដាលនៃជំងឺកូវីដ ១៩ ទ្រង់ទ្រាយធំនៅក្នុងរោង

ចក្រមួយចំនួន ម្ចាស់រោងចក្រទាំងនោះមិនត្រូវបានកាត់ឱ្យជាប់ទោសនោះទេ ក៏ប៉ុន្តែការកាត់ទោសលើកូដករជាស្ត្រីធ្វើឡើងគឺដើម្បីបំបិទការបញ្ចេញមតិដែលរដ្ឋាភិបាលមិនចូលចិត្ត។

## ២) សេរីភាពនៃការបញ្ចេញមតិ

រដ្ឋាភិបាលបានបន្តឃុំខ្លួនស្ត្រីផ្សេងទៀតចំពោះការដែលពួកគេហាននិយាយចំៗឥតសំចៃមាត់។ គិតត្រឹមឆ្នាំ ២០២២ ដែលការបោះឆ្នោតឃុំសង្កាត់ជិតឈានចូលមកដល់ អ្នកស្រី សំ សុខា ដែលត្រូវបានកាត់ឱ្យជាប់ពន្ធនាគារនៅក្នុងឆ្នាំ២០១៧ចំពោះការគប់ស្បែកជើងលើផ្ទាំងបដាឃោសនាបោះឆ្នោតមួយនៅអំឡុងពេលបោះឆ្នោតអាណត្តិមុន ដែលការអនុវត្តទោសរយៈពេល ៤ ឆ្នាំរបស់គាត់បានឈានដល់ទីបញ្ចប់ នៅចុងឆ្នាំ២០២១។ សមាជិកបីរូបនៃក្រុមបរិស្ថានរបស់អង្គការមាតាធម្មជាតិ កញ្ញា ស៊ុន រដ្ឋា កញ្ញា យឹម លៀងហ៊ី និង លី ចាន់ដារាវុធ ត្រូវបានចាប់ខ្លួននៅក្នុងឆ្នាំ២០២១ ដោយត្រូវបានចោទប្រកាន់ពីបទរំលោភលើច្បាប់បើទោះជាពាក្យសម្ដីត្រូវបាននិយាយនៅក្នុងកិច្ចប្រជុំមួយតាមកម្មវិធី Zoom ដែលមានលក្ខណៈឯកជនក៏ដោយ។ ថ្វីត្បិតតែសកម្មជនទាំងនេះ រួមទាំងសមាជិកមាតាធម្មជាតិបីនាក់ផ្សេងទៀតត្រូវបានឃុំខ្លួនពីមុន មាន កញ្ញា ធន់ រដ្ឋា កញ្ញា ភួន កែវរស្មី និងកញ្ញា ឡុង គន្ធា ត្រូវបានដោះលែងពីពន្ធនាគារនៅចុងឆ្នាំ២០២១ក៏ដោយ ក៏បទចោទរបស់ពួកគេ មិនត្រូវបានទម្លាក់ចោលនៅឡើយ។ ពាក់កណ្ដាលនៃក្រុមអ្នកធ្វើយុទ្ធនាការបរិស្ថាន គឺជាស្ត្រី ហើយពួកគេទាំងអស់បានធ្វើការចងក្រងឯកសារ និងធ្វើការផ្សព្វផ្សាយការយល់ដឹងដោយសន្តិវិធី អំពីការខូចខាតបរិស្ថានដោយគម្រោងអភិវឌ្ឍន៍នៅកម្ពុជា។

រាជរដ្ឋាភិបាលបន្តរឹតបន្តឹងបន្ថែមទៀតលើសេរីភាពនៃការសម្ដែងមតិនៅក្នុងខែគុម្ភៈ ឆ្នាំ២០២១ ដោយអនុម័តអនុក្រិត្យស្ដីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិ ដែលក្នុងនោះមានបទបញ្ញត្តិមួយបានផ្ដល់អំណាចដែលមិនធ្លាប់មានពីមុនដល់រាជរដ្ឋាភិបាលក្នុងការត្រួតពិនិត្យ និងគ្រប់គ្រងលើការធ្វើទំនាក់ទំនងរបស់ពលរដ្ឋសាមញ្ញ។ អនុក្រិត្យនេះគ្រោងនឹងដាក់ឱ្យអនុវត្តនៅក្នុងឆ្នាំ២០២២ ប៉ុន្តែនៅក្នុងឆ្នាំ២០២១ មានមនុស្សយ៉ាងតិច ៣៩នាក់ហើយដែលក្នុងចំណោមនោះ ភាគច្រើនគឺជាស្ត្រីត្រូវបានចាប់ខ្លួន ឃុំខ្លួន ឬកំពុងស្វែងរកចាប់ខ្លួនដោយអាជ្ញាធរសម្រាប់ការធ្វើទំនាក់ទំនងតាមប្រព័ន្ធផ្សព្វផ្សាយសង្គម ដែលការធ្វើទំនាក់ទំនងបែបនេះគួរជាការសន្ទនាដែលត្រូវបានទទួលការការពារស្របទៅតាមរដ្ឋធម្មនុញ្ញរបស់កម្ពុជា។[3]

## ៣) សេរីភាពនៃការបង្ហាញភាពជាខ្លួនឯង

រាជរដ្ឋាភិបាលកំពុងបន្តរក្សាជម្រើសរបស់ខ្លួនចំពោះការអនុម័តច្បាប់ថ្មីនានាដើម្បីរឹតបន្តឹងសេរីភាពនៃការបង្ហាញចេញរបស់ស្ត្រី ជាពិសេសពាក់ព័ន្ធនឹងរបៀបនៃការស្លៀកពាក់ និងការបង្ហាញភាពជាខ្លួនឯងរបស់ស្ត្រីតាមប្រព័ន្ធអនឡាញ។ បើទោះជាសេចក្ដីព្រាងច្បាប់ស្ដីពីសណ្ដាប់ធ្នាប់សាធារណៈ (DLPO) មិនទាន់ត្រូវបានអនុម័តកាលពីឆ្នាំមុនក្ដី ក៏សេចក្ដីព្រាងច្បាប់នេះនៅមិនទាន់ជាជម្រើសដែលត្រូវលុបចោលនោះឡើយ។ មាត្រា ៣៦ នៃសេចក្ដីស្នើច្បាប់នេះបានចែងអំពី "ការការពារសេចក្ដីថ្លៃថ្នូររបស់ជាតិ" ដែលផ្អែកលើទស្សនៈបែបបិតាធិបតេយ្យលើស្ត្រីកម្ពុជា ដែលថាស្ត្រីកម្ពុជាគួរមានចរិកសុភាពរាបសា និងរំទុំ ព្រមទាំងហាមឃាត់ស្ត្រីមិនឱ្យស្លៀកសម្លៀក

---
[3] Cambodian Center for Human Rights (CCHR) monitoring data.

បំពាក់ "ខ្លីខើចលើខើចក្រោម" ឬ "ស្តើងមើលឃើញកេរភេទ ឬបង្ហាញផ្នែកខ្លះនៃកេរភេទ" ដែលនេះគឺជាការលើកឡើងដោយមិនសមហេតុសមផលពីសំណាក់មន្ត្រីរដ្ឋាភិបាល។ សាធារណៈជនទូទៅ និងអង្គការសង្គមស៊ីវិលបានធ្វើការជំទាស់យ៉ាងខ្លាំង ក្នុងការរារាំងមិនឱ្យមានការអនុម័តច្បាប់នេះភ្លាមៗ ឡើយ។

ទោះជាយ៉ាងនេះក្តី ក្នុងឆ្នាំ២០២១ មានការប៉ុនប៉ងជាថ្មីក្នុងការរឹតបន្តឹងលើការបង្ហាញភាពជាខ្លួនឯងរបស់ស្ត្រីដោយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្នុងនោះក៏ធ្លាប់មានស្ត្រីជាសិល្បករម្នាក់ត្រូវបានព្យួរពីការងារដោយសារតែការស្លៀកសម្លៀកបំពាក់ដែលត្រូវបានចាត់ទុកថាមាននលក្ខណៈ "ស៊ិចស៊ីពេក" ដូច្នេះហើយទើបត្រូវបានចោទប្រកាន់ថាប្រឆាំងទៅនឹងវប្បធម៌ប្រពៃណីខ្មែរ។ កាលពីខែធ្នូ ឆ្នាំ២០២១ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈបានប្រកាសថាក្រសួងកំពុងពិចារណាក្នុងការអនុម័តក្រមប្រត្តិវប្បធម៌ សម្រាប់គ្រប់គ្រងសកម្មភាពទាំងឡាយរបស់សាធារណជនទូទៅ ដែលធ្វើអោយប៉ះពាល់ដល់តម្លៃវប្បធិមជាតិ ។[4] វិសាលភាពនៃសេចក្តីព្រាងច្បាប់នេះនឹងអនុវត្តលើសាធារណជនធម្មតាទាំងអស់ដែលធ្វើទង្វើណាមួយប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់វប្បធម៌ និងប្រពៃណីជាតិ។[5] នេះគឺជាការព្រួយបារម្ភមួយដែលក្រមបែបនេះប្រហែលជានឹងប្រើប្រាស់ជាគោលដៅចំបងចំពោះតែស្ត្រី និងបុគ្គលអ្នកស្រលាញ់ភេទដូចគ្នាប៉ុណ្ណោះ។ ដើម្បីអាចដកច្បាប់ស្រី (ក្រមប្រតិបត្តិបែបប្រពៃណីសម្រាប់ស្ត្រី តែមិនមែនជាច្បាប់ទេ) ចេញពីប្រព័ន្ធអប់រំនៅស្ទើរគ្រប់សាលាទាំងអស់បាននោះ គឺត្រូវចំណាយពេលជាច្រើនឆ្នាំណាស់មកហើយក្នុងការបញ្ចុះបញ្ចូល និងអប់រំ ប៉ុន្តែនាពេលថ្មីៗនេះ បែរជាមានស្ត្រីមួយចំនួនត្រូវបានចាប់ខ្លួនពីបទរំលោភលើបទដ្ឋានសង្គមបែបប្រពៃណី និងប្រកបដោយការរើសអើងទៅវិញបើទោះជាពុំទាន់មានច្បាប់ជាក់លាក់ណាមួយចូលជាធរមានក៏ដោយ។ បច្ចុប្បន្ននេះ បទបញ្ញត្តិស្តីពីរូបភាព និងសម្ភារៈអាសអាភាសនៅក្នុងច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្ស ដែលជាច្បាប់មួយមានគោលបំណងជាក់លាក់ក្នុងការការពារស្ត្រីពីការកេងប្រវ័ញ្ចដោយត្រូវបានបង្ខំឱ្យបង្ហោះរូបភាពអាសអាភាសនោះ បែរជាត្រូវបានយកមកប្រើដើម្បីដាក់ស្ត្រីដែលគួរតែការពារឱ្យជាប់ពន្ធនាគារទៅវិញ។ ការប្រើប្រាស់ច្បាប់ជាអាវុធប្រឆាំងនឹងសិទ្ធិក្នុងការជ្រើសរើស និងសិទ្ធិស្វ័យសំរេចរបស់ស្ត្រី គឺជាមធ្យោបាយមួយដែលបន្តអោយមានការបង្ក្រាបលើសិទ្ធិពលរដ្ឋ និងសេរីភាពជាមូលដ្ឋាននៅក្នុងប្រទេសកម្ពុជា។

បទដ្ឋានប្រចាំថ្ងៃ ដែលផ្អែកទៅលើសេចក្តីព្រាងច្បាប់ទាំងនេះ ត្រូវបានចាត់ទុកថាជាសីលធម៌ខ្មែរ ដោយពលរដ្ឋមិនបានដឹង ឬមិនបានកត់សម្គាល់ថា ក្រមសីលធម៌ទាំងនេះមានលក្ខណៈលម្អៀងទៅខាងបុរសហើយមានលក្ខណៈរើសអើងលើស្ត្រី និងបុគ្គលមិនកំណត់អត្តសញ្ញាណយេនឌ័រឡើយ។ បទដ្ឋានទាំងនេះពង្រឹងឡើងវិញនូវសុពលភាពនៃបទដ្ឋានយេនឌ័របែបប្រពៃណីដែលបានកំណត់តួនាទីនៃភាពជាអ្នកដឹកនាំ និងអំណាចដល់បុរស ចំណែកតួនាទីជាអ្នកមើលថែទាំត្រូវធ្លាក់ទៅលើស្ត្រី។ ហេតុដូច្នេះហើយ ទើបសេចក្តីព្រាងច្បាប់បែបនេះធ្វើអោយ

---

[4] https://thmeythmey.com/?page=detail&id=110232

[5] David, S., Marza, C. (December 2021). Phnom Penh Post: A Ministry of Culture and Fine Arts Advisor to Suggest Implementing a Cultural Code of Conduct. Phnom Penh Post. Available at https://cambodianess.com/article/a-ministry-of-culture-and-fine-arts-advisor-to-suggest-implementing-a-cultural-code-of-conduct accessed in January 2021.

បទដ្ឋានយេនឌ័រដែលមានលក្ខណៈរើសអើងដោយផ្អែកលើភេទ ចាក់ឫសកាន់តែជ្រៅបណ្តោលអោយប៉ះពាល់ដោយមិនស្មើភាពលើស្ត្រី និងកុមារី ព្រមទាំងបុគ្គលដែលមិនកំណត់អត្តសញ្ញាណយេនឌ័រ ហើយក៏កំហិតសិទ្ធិសេរីភាពរបស់ពួកគេបន្ថែមទៀតផងដែរ។

## ស្ត្រីនៅក្នុងពន្ធនាគារ

អង្គការលីកាដូបានត្រួតពិនិត្យពន្ធនាគារចំនួន ១៩កន្លែងក្នុងចំណោមពន្ធនាគាចំនួន២៨កន្លែងនៅក្នុងប្រទេសកម្ពុជា ដែលបានដាក់អ្នកទោសចំនួន៣២៧១៩នាក់ គិតត្រឹមខែធ្នូ ឆ្នាំ២០២១។ នៅក្នុងចំណោមអ្នកទោសទាំងនេះ មានអ្នកទោសចំនួន ២៣៤៣៦នាក់ កំពុងស្ថិតក្នុងការឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការ ឬកំពុងរង់ចាំសេចក្តីសម្រេចចុងក្រោយពីតុលាការ (ស្មើនឹង ៧១%នៃចំនួនមនុស្សសរុបដែលបានឃុំខ្លួន) គិតត្រឹមខែធ្នូ ឆ្នាំ ២០២១ ។ បើទោះបីជាមានកិច្ចប្រឹងប្រែងដោះស្រាយរឿងក្តីត្រូវបានធ្វើឡើងដោយក្រសួងពាក់ព័ន្ធនានា ក៏ចំនួននៃការឃុំខ្លួនថ្មី និងការបន្តអនុវត្តការដាក់ពន្ធនាគារលើមនុស្សដោយមិនចាំបាច់ ខណៈករណីរបស់ពួកគេស្ថិត ក្នុងការរង់ចាំការជំនុំជម្រះនោះក្តីនេះ មានន័យថាបញ្ហាកកស្ទះណែនណាន់ចង្អៀតនៅក្នុងពន្ធនាគារនៅមិនទាន់ត្រូវបានកែលម្អនៅឡើយ។ មាន ១៥ពន្ធនាគារក្នុងចំណោម ១៩ពន្ធនាគារដែលអង្គការលីដាដូបានត្រួតពិនិត្យ បានផ្ទុកអ្នកទោសលើសចំណុះនៅចុងឆ្នាំ ដោយខេត្តកំពតមានលើសរហូតដល់ ៥០៤% និងខេត្តកណ្តាលមាន ៤៦៣% ។ ក្នុងឆ្នាំ២០២១ មានកុមារចំនួន ១៧៩នាក់ (ក្មេងស្រីចំនួន ៨៤ និងក្មេងប្រុសចំនួន ៩៥នាក់) ដែលត្រូវទៅតាមម្តាយរបស់ពួកគេក្នុងពន្ធនាគារ និងមានស្ត្រីមានផ្ទៃពោះចំនួន ៤៧នាក់ ត្រូវបានឃុំខ្លួននៅក្នុងពន្ធនាគារដែលត្រួតពិនិត្យដោយអង្គការលីកាដូចំនួន ១៩កន្លែង ។

ការបូកបញ្ចូលគ្នានៃការរីករាលដាលនៃការចម្លងមេរោគកូវីដ ១៩ នៅក្នុងសហគមន៍ក្នុងឆ្នាំ ២០២១ ព្រមទាំងកង្វះខាតនៃការរក្សាគម្លាត និងការខកខាននៃការផ្តល់អនាម័យឱ្យបានគ្រប់គ្រាន់ ដូចជា សាប៊ូលាងដៃនោះ មានន័យថា ពន្ធនាគារមិនអាចមានលទ្ធភាពធ្វើឱ្យអ្នកជាប់ឃុំឃាំងមានសុវត្ថិភាពពីជំងឺកូវីដ ១៩នោះទេ។ ចំណុចវិជ្ជមាននោះគឺថា បើទោះជាគ្មានការការពារពីការឆ្លងមេរោគក៏ដោយ ក៏មានយុទ្ធនាការចាក់វ៉ាក់សាំងរបស់រដ្ឋាភិបាលដល់ពន្ធនាគារផងដែរ។ ស្ត្រីមានផ្ទៃពោះម្នាក់ៗនៅក្នុងមណ្ឌលកែប្រែ២ បានទទួលវ៉ាក់សាំងកូវីដ ១៩ ចំនួនពីរដងនៅមណ្ឌលជាតិគាំពារមាតា និងទារក។ យោងតាមទិន្នន័យរបស់រដ្ឋាភិបាល ស្ត្រីមានផ្ទៃពោះដែលជាប់ឃុំនៅសល់ក៏បានទទួលវ៉ាក់សាំងផងដែរ។ ក្នុងឆ្នាំ២០២១ វ៉ាក់សាំង មិនទាន់ត្រូវបានអនុញ្ញាតចាក់ឱ្យកុមារនៅក្រោមអាយុ៥ឆ្នាំនៅឡើយ ហើយដោយហេតុថា កុមារទាំងអស់ដែលរស់នៅជាមួយម្តាយរបស់ពួកគេនៅមណ្ឌលកែប្រែ២ ស្ថិតក្រោមអាយុ៥ឆ្នាំ ដូច្នេះពួកគេមិនអាចទទួលបានវ៉ាក់សាំងនៅឡើយ។

## អំពើហិង្សាផ្អែកលើយេនឌ័រ

អំពើហិង្សាផ្អែកលើយេនឌ័រមានន័យទូលំទូលាយ ក្នុងនោះរួមបញ្ចូលទាំងអំពើរំលោភសេពសន្ថវៈ អំពើបៀតបៀនផ្លូវភេទ (នៅកន្លែងការងារ សាលារៀន និងនៅទីសាធារណៈ) អំពើហិង្សាក្នុងគ្រួសារ រួមមានការបៀតបៀនកុមារ ការបៀតបៀនសមាជិកគ្រួសារ អំពើហិង្សាលើដៃគូស្និទ្ធស្នាល អំពើជួញដូរមនុស្សនិងការធ្វើអាជីវកម្មផ្លូវភេទ និងអំពើហិង្សាដែលគាំទ្រដោយរដ្ឋ។ កុមារី និងស្ត្រីជាច្រើន រួមទាំងបុគ្គលដែលមិនកំណត់អត្តសញ្ញាណយេនឌ័រនៅក្នុងប្រទេសកម្ពុជា មិនត្រឹមតែទទួលរងជាប្រចាំនូវទម្រង់នៃអំពើហិង្សាផ្អែកលើយេនឌ័រប៉ុណ្ណោះទេ ពួកគេក៏ប្រឈមនឹងឧបសគ្គជាច្រើនក្នុងការទទួលបានសេវានានា និងយុត្តិធម៌ មិនថាតាមរយៈប្រព័ន្ធយុត្តិធម៌ផ្លូវការ ឬយន្តការដោះស្រាយជម្លោះតាមជម្រើសនោះទេ។

### ១) ស្ថិតិអំពីអំពើហិង្សាផ្អែកលើយេនឌ័រសម្រាប់ឆ្នាំ២០២១

យោងតាមទិន្នន័យដែលប្រមូលបានតាមរយៈការត្រួតពិនិត្យតាមប្រព័ន្ធផ្សព្វផ្សាយប្រចាំខែដោយអង្គការអាក់សិនអេត កម្ពុជា (ActionAid) ចំនួនជាមធ្យមនៃអំពើរំលោភសេពសន្ថវៈ ករណីអំពើហិង្សាក្នុងគ្រួសារ និងអំពើវាយប្រហារលើស្ត្រី និងកុមារី ដែលរាយការណ៍ដោយប្រព័ន្ធផ្សព្វផ្សាយពត៌មានផ្លូវការ គិតជាប្រចាំខែនៅក្នុងឆ្នាំ ២០២១ គឺមានចំនួនពីចន្លោះ៣៥ ទៅ ៤០ ករណី។ អង្គការ ActionAid បានសង្កេតឃើញថា មាននិន្នាការមួយចំនួនដូចជា ១) ការកើនឡើងនៃចំនួនរាយការណ៍អំពីអំពើការបំពានផ្លូវភេទ និងអំពើរំលោភសេពសន្ថវៈលើស្ត្រីវ័យក្មេងក្នុងនោះរួមទាំង អំពើរំលោភសេពសន្ថវៈដែលប្រព្រឹត្តឡើងលើសាច់ឈាមបង្កើតខ្លួនឯង បើធៀបនឹងឆ្នាំមុនៗ និង ២) អំពើមនុស្សឃាតទៅលើដៃគូ មានចំនួន៥០% នៃការរាយការណ៍ដែលបានផ្សព្វផ្សាយដោយប្រព័ន្ធផ្សព្វផ្សាយអំពីករណីអំពើហិង្សាលើដៃគូស្និតស្នាល។ ភាគច្រើននៃជនល្មើស គឺមានទំនាក់ទំនងជិតស្និតជាមួយជនរងគ្រោះ ឬអ្នកនៅរស់រានមានជីវិត។[6] បើទោះជាភាគច្រើននៃករណីអំពើហិង្សាលើស្ត្រី និងកុមារី ដែលត្រូវបានរាយការណ៍ដោយប្រព័ន្ធផ្សព្វផ្សាយនោះបានកើតឡើងនៅរាជធានីភ្នំពេញក៏ដោយ ក៏ទិន្នន័យដែលប្រមូលបានដោយក្រុមការងារធ្វើការលើបញ្ហាអំពើហិង្សាផ្អែកលើយេនឌ័រ ដែលជាសមាជិកនៃ NGO-CEDAW បានបង្ហាញថាអត្រានៃអំពើហិង្សាក៏មានចំនួនខ្ពស់ផងដែរនៅតាមទីជនបទ។ អង្គការសង្គមស៊ីវិលដែលធ្វើការដោយផ្ទាល់ជាមួយសហគមន៍នៅថ្នាក់ក្រោមជាតិ បានធ្វើកំណត់ហេតុចំនួន ១១៤ករណីនៃអំពើហិង្សាលើស្ត្រី និងកុមារី នៅក្នុងខេត្តពោធិ៍សាត់ [7] ១០៤ករណីនៃអំពើហិង្សាលើស្ត្រី និងកុមារី នៅក្នុងខេត្តសៀមរាប និង៨៣ករណីនៃអំពើហិង្សាលើស្ត្រី និងកុមារី នៅខេត្តបាត់ដំបង។[8] ទម្រង់នៃអំពើហិង្សាលើស្ត្រី និងកុមារី ជាច្រើនត្រូវបានរាយការណ៍ដោយប្រព័ន្ធផ្សព្វផ្សាយដោយការគ្របដណ្តប់នៃប្រព័ន្ធផ្សព្វផ្សាយទាំងនេះ ផ្តោតលើអំពើហិង្សាលើរាងកាយ (៥១%) និងអំពើហិង្សាផ្លូវភេទ (៤៥%)។ តួលេខនេះស្របគ្នាទៅនឹងប្រភេទនៃអំពើហិង្សាដែលត្រូវបានរាយការណ៍នៅកម្រិតសហគមន៍។ ដោយ

[6] https://www.facebook.com/safecitiesforwomencambodia/posts/2939209179690474/ ActionAid's report for April and May 2021 showed 1 case of GBV against a man and 40 against women and girls from 9 Khmer language media outlets.
[7] Information provided by ActionAid Cambodia and the Provincial Department of Women's Affairs
[8] Information provided by Banteay Srey and the Provincial Department of Women's Affairs

សារការសិក្សាស្រាវជ្រាវអំពីអំពើហិង្សាបានបង្ហាញថា អំពើហិង្សាផ្លូវចិត្ត និងអំពើហិង្សាផ្នែកសេដ្ឋកិច្ចត្រូវបានគេចាត់ទុកថាជាបញ្ហាធម្មតា ដែលកត្តានេះឆ្លុះបញ្ចាំងពីផ្នត់គំនិតបែបប្រពៃណីដោយចាត់ទុកថាមានតែអំពើហិង្សាលើរូបរាងកាយ ដែលបង្ករបួសស្នាមអាចមើលឃើញនឹងភ្នែក និងអំពើហិង្សាផ្លូវភេទប៉ុណ្ណោះ ដែលគួរនឹងធ្វើការរាយការណ៍។

អង្គការសង្គមស៊ីវិលដែលបានចូលរួមចំណែកក្នុងការរៀបចំរបាយការណ៍នេះ បានប្រមូលភស្តុតាងពីស្ត្រី និងកុមារី ដែលទទួលរងផលប៉ះពាល់ជាអវិជ្ជមានពីការរីករាលដាលនៃមេរោគកូវីដ ១៩ ទៅលើសុវត្ថិភាពផ្លូវកាយ និងសុខភាពផ្លូវចិត្តរបស់ពួកគេ។ បញ្ហានេះមានសភាពធ្ងន់ធ្ងរខ្លាំងនៅពេលដែលពួកគេត្រូវបានកាត់ផ្តាច់ពីប្រព័ន្ធគាំពារសង្គមរបស់ពួកគេ មិនតែប៉ុណ្ណោះការទទួលបានសេវាផ្សេងៗក៏មានកម្រិត ដោយសារការដាក់កំហិតលើការធ្វើដំណើរនៅអំឡុងពេលបិទខ្ទប់ និងបន្តអនុវត្តការរក្សាគម្លាតសង្គម ដែលដាក់ចេញដោយរដ្ឋាភិបាល។

អង្គការមិនមែនរដ្ឋាភិបាលមួយដែលចូលរួមចំណែកក្នុងរបាយការណ៍នេះ បានសង្កេតឃើញថា ការរាយការណ៍ពីអំពើរំលោភសេពសន្ថវៈបានកើនឡើងពី ៣៥ករណី ក្នុងឆ្នាំ២០២០ ទៅដល់ ៤២ករណីនៅក្នុងឆ្នាំ២០២១ នៅតាមបណ្តារខេត្តគោលដៅរបស់ខ្លួន។ អង្គការមិនមែនរដ្ឋាភិបាលនេះ ក៏បានសង្កេតឃើញផងដែរថាមានការថយចុះនូវអំពើហិង្សាលើរូបរាងកាយក្នុងចំណោមក្រុមមនុស្សវ័យក្មេងនៅតាមតំបន់គោលដៅរបស់ខ្លួននៅក្នុងឆ្នាំ ២០២១ ធៀបនឹងទិន្នន័យបឋមរបស់ខ្លួន។ ថ្វីត្បិតតែយ៉ាងនេះក៏ដោយក៏ចំនួនករណីនៃអំពើហិង្សាលើរូបរាងកាយនៅតែមានអត្រាខ្ពស់ គឺ ៣៧.៩% ផ្អែកតាមទិន្នន័យនេះ ក៏បានបង្ហាញបន្ថែមទៀតថា ចំនួនស្ត្រីវ័យក្មេងដែលទទួលរងអំពើហិង្សា មានកម្រិតច្រើនជាងបុរសវ័យក្មេង (ស្ត្រីមាន៣៩.១% និងបុរស៣៦.៤%)។ បន្ថែមពីលើនេះ ការសិក្សាដូចគ្នានេះដែរបានបង្ហាញថាយុវជនកម្ពុជា មានការយល់ដឹងកាន់តែច្រើនអំពីវត្តមាននៃសេវា និងយន្តការនានាដែលឆ្លើយតបទៅនឹងអំពើហិង្សាផ្អែកលើយេនឌ័រ ដែលពួកគេអាចស្វែងរកបាននៅក្នុងសហគមន៍របស់ពួកគេ (៧៣.៩%)។[9]

## ២) ស្រមោលនៃការរីករាលដាលនៃអំពើហិង្សាផ្អែកលើយេនឌ័រនៅក្នុងបរិបទនៃមេរោគកូវីដ ១៩

ក្តីកង្វល់ដ៏សំខាន់ជាសកលមួយដែលបណ្តាលមកពីការបិទខ្ទប់ និងការដាក់កំហិតលើការធ្វើដំណើរបានក្លាយជាការរីករាលដាលនៃអំពើហិង្សាផ្អែកលើយេនឌ័រ ដែលធ្វើឱ្យស្ត្រី និងកុមារី ស្ថិតក្នុងហានិភ័យកាន់តែខ្ពស់ ដោយសារតែត្រូវបានបង្ខាំងនៅក្នុងផ្ទះជាមួយជនប្រព្រឹត្តអំពើបៀតបៀនមកលើពួកគេ ហើយក៏បានកាត់បន្ថយឱកាសក្នុងការទទួលបានសេវា និងការរាយការណ៍ពីអំពើហិង្សា ដោយសារការបិទកន្លែងធ្វើការ និងសាលារៀន។ របាយការណ៍រួមមួយនៅក្នុងខែមីនា ឆ្នាំ២០២១ ធ្វើឡើងដោយរដ្ឋាភិបាលកម្ពុជា អង្គការ UNICEF និង អង្គការ Save the Children បានរកឃើញថា ក្មេងស្រីចំនួន១៧% មានអារម្មណ៍ថា ខ្លួនស្ថិតនៅក្នុងហានិភ័យបន្ថែមទៀតនៃការទទួលរងអំពើហិង្សា ពលកម្មកុមារ អាពាហ៍ពិពាហ៍កុមារ និងបទល្មើសលើកុមារ។ ការសិក្សានេះបានបង្ហាញថា ៣០%នៃបុគ្គលិកផ្តល់ការថែទាំ ៣២%នៃបុគ្គលិកផ្នែករដ្ឋបាលមូលដ្ឋាន ៦៤% នៃបុគ្គលិករដ្ឋបាលខាងផ្នែកអប់រំ និង

[9] Ibid.

៥៩%នៃគ្រូបង្រៀន ជឿជាក់ថា ក្មេងស្រីនឹងប្រឈមហានិភ័យបន្ថែមទៀត។[10] ក្រៅពីនេះ បុគ្គលិកខាងផ្នែកផ្តល់សេវានៅក្នុងខេត្តរតនគិរី និងខេត្តមណ្ឌលគិរី បានមើលឃើញថា មានការកើនឡើងនៃចំនួនអាពាហ៍ពិពាហ៍កុមារនៅក្នុងអំឡុងពេលវិបត្តិកូវីដ-១៩។[11] តំបន់ភាគច្រើននៃខេត្តទាំងពីរនេះ ជាទីជនបទ ដែលមានចំនួនប្រជាពលរដ្ឋជនជាតិដើមភាគតិចខ្ពស់។

## ៣) អំពើជួញដូរមនុស្ស

នៅក្នុងឆ្នាំ ២០២១ មានការកើនឡើងនៃករណីជួញដូរមនុស្ស និងករណីធ្វើអាជីវកម្មផ្លូវភេទ ដែលពត៌មាននេះផ្តល់ដោយក្រសួងមហាផ្ទៃ។ ក្នុងរយៈពេល ៦ខែដំបូងនៃឆ្នាំ២០២១ មាន ១៩៨ករណី ធៀបនឹងរយៈពេល៦ខែដំបូងនៃឆ្នាំ ២០២០ មានត្រឹមតែ ៦៣ករណី។[12] បន្ថែមពីលើនេះ មានស្ត្រីកម្ពុជាជាង ៣០០នាក់ ត្រូវបានជួយសង្គ្រោះពីការជួញដូរទៅប្រទេសចិន នៅក្នុងរយៈ៩ខែដំបូងនៃឆ្នាំ ២០២១ ចំនួននេះមានការកើនឡើងជាងពីរដងធៀបនឹងរយៈពេលពេញមួយឆ្នាំនៃឆ្នាំ២០២០។[13] តាមរបាយការណ៍របស់ការិយាល័យប្រឆាំងនឹងការជួញដូរមនុស្សរបស់សហរដ្ឋអាមេរិកសម្រាប់ឆ្នាំ២០២១ បានដាក់ចំណាត់ថ្នាក់ប្រទេសកម្ពុជាជាប្រទេសស្ថិតនៅកម្រិត ២ (Tier ២) ដែលចាំបាច់ត្រូវធ្វើការស៊ើបអង្កេត ដោយសារអំពើជួញដូរមនុស្សកំពុងបន្តកើតមាន។ យោងតាមរបាយការណ៍នេះ បានកត់សម្គាល់កិច្ចខិតខំប្រឹងប្រែងមួយចំនួនដែលធ្វើឡើងដោយរាជរដ្ឋាភិបាលកម្ពុជា មានដូចជា ការកែលម្អលើការប្រមូលទិន្នន័យ និងការត្រួតពិនិត្យលើដំណើរការនៃការប្តឹងចោទប្រកាន់ និងការកាត់ទោសជនល្មើសនៃអំពើជួញដូរមនុស្សក៏ដូចជាធ្វើការកែលម្អទិន្នន័យកំណត់អត្តសញ្ញាណជនរងគ្រោះពេញទូទាំងប្រទេស ធ្វើការបន្តស៊ើបអង្កេត ប្តឹងចោទប្រកាន់ និងកាត់ទោសជនល្មើសនៃអំពើជួញដូរមនុស្ស ព្រមទាំងបន្តអនុវត្តផែនការសកម្មភាពជាតិក្នុងការបង្ក្រាបអំពើជួញដូរមនុស្ស។[14] ទោះជាយ៉ាងនេះក្តី របាយការណ៍នេះក៏បានបង្ហាញផងដែរថា ពុំមានការកែលម្អគួរឱ្យកត់សម្គាល់កាលពីឆ្នាំកន្លងទៅនោះទេ ហើយថាអំពើពុករលួយបានធ្វើឱ្យបណ្តឹងចោទប្រកាន់ជាច្រើនមិនទទួលបានការស៊ើបអង្កេត និងក៏ធ្វើឱ្យជនល្មើសមួយចំនួនទទួលបានការអនុញ្ញាតឱ្យរត់គេចពីការដាក់ទោសទណ្ឌផងដែរ។ របាយការណ៍នេះ បង្ហាញទៀតថា កម្ពុជានឹងធ្លាក់ទៅដល់កម្រិត ៣ (Tier 3) ប្រសិនបើរាជរដ្ឋាភិបាលមិនអនុវត្តផែនការសកម្មភាពជាលាយលក្ខអក្សររបស់ខ្លួននាពេលខាងមុខនោះទេ។

## ៤) អំពើបៀតបៀនតាមប្រព័ន្ធអនឡាញទៅលើស្ត្រី កុមារី និងបុគ្គលមិនកំណត់អត្តសញ្ញាណយេនឌ័រណាមួយ

អំពើបៀតបៀនតាមប្រព័ន្ធអនឡាញក្នុងគ្រប់ទម្រង់ច្រើនបែបច្រើនយ៉ាងអាចកើតមានឡើងលើមនុស្សគ្រប់រូប នៅគ្រប់ទីកន្លែង ដោយមិនគិតពីអត្តសញ្ញាណយេនឌ័រ និងទំនោរផ្លូវភេទរបស់ពួកគេ ហើយអំពើបៀតបៀននេះក៏មិនមែនកើតមានឡើងទៅលើតែស្ត្រី និងកុមារីទាំងស្រុងនោះទេ។ ទោះជាយ៉ាងណាក៏ដោយនៅក្នុងសង្គមរបស់យើងដែលពោរពេញទៅដោយការប្រកាន់ភ្ជាប់នូវផ្នត់គំនិតយេនឌ័របែបអវិជ្ជមាននោះ ធ្វើឱ្យស្ត្រី កុមារី និង

[10] Cambodia COVID-19 Joint Education Needs Assessment, March 2021, p. 44
[11] https://cambojanews.com/experts-fear-child-marriage-on-the-rise-in-ratanakiri-and-mondulkiri-amid-covid-19-pandemic/
[12] https://www.khmertimeskh.com/50924773/cambodia-sees-spike-in-human-sex-trafficking-cases-in-first-half-of-2021/
[13] https://vodenglish.news/bride-rescues-from-china-number-more-than-one-a-day/

[14] https://www.state.gov/wp-content/uploads/2021/07/TIP_Report_Final_20210701.pdf Page 156.

អ្នកមិនកំណត់អត្តសញ្ញាណយេនឌ័រ ជាអ្នកងាយនឹងទទួលរងគ្រោះនូវអំពើបៀតបៀនបែបនេះច្រើនជាងគេ។ មិនតែប៉ុណ្ណោះអ្នកដែលធ្វើយុទ្ធនាការទាមទារឱ្យមានសមភាពយេនឌ័រ ជារឿយៗកាន់តែក្លាយទៅជាគោលដៅ ហើយទទួលរងនូវការគម្រាមកំហែងដោយផ្ទាល់ដល់អាយុជីវិត និងក្រុមគ្រួសាររបស់ពួកគេ។ កត្តានេះបានរួមចំណែកក្នុងការបំបិទសម្លេងរបស់ពួកគេ ដោយជំរុញពួកគេឱ្យនៅឆ្ងាយទាំងស្រុងពីលំហាឌីជីថល ឬបង្ខំខ្លួនឯងឱ្យអនុវត្តការកំហិតលើខ្លួនឯង មកប្រើជាយន្តការដោះស្រាយទៅវិញ។

អង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ ថ្មីៗនេះបានចេញផ្សាយរបាយការណ៍មួយមានចំណងជើងថា "បច្ចុប្បន្នភាពស្ថានភាព៖ ការបៀតបៀនតាមប្រព័ន្ធផ្សព្វផ្សាយសង្គមនៅកម្ពុជា" ដែលក្នុងនោះបានរកឃើញថា ការបៀតបៀនផ្លូវភេទ និងការរើសអើង គឺជាប្រភេទនៃការបៀតបៀនតាមប្រព័ន្ធអនឡាញច្រើនជាងគេបំផុត នៅក្នុងឆ្នាំ២០២១ ហើយមាន៣៨%នៃអ្នកចូលរួមស្ទង់មតិនេះ ធ្លាប់ទទួលរងការបៀតបៀនតាមប្រព័ន្ធអនឡាញ។ ស្ត្រី និងប្រុស បានរាយការណ៍ពីការបៀតបៀនតាមប្រព័ន្ធអនឡាញក្នុងកម្រិតអត្រាស្មើគ្នា ក៏ប៉ុន្តែអត្រានៃការបៀតបៀនខ្ពស់ជាងគេបំផុត គឺត្រូវបានរាយការណ៍ដោយក្រុមអ្នកស្រឡាញ់ភេទដូចគ្នា សកម្មជន និងយុវជន។ លើសពីនេះ ៥៩%នៃអ្នកចូលរួមទាំងអស់ បានស្គាល់មនុស្សដែលធ្លាប់ទទួលរងការបៀតបៀន ហើយនៅក្នុងករណីភាគច្រើនបំផុតនោះ ក្នុងចំណោមមនុស្សដែលគេស្គាល់នេះគឺជាស្ត្រី។ ជាពិសេស ២៩% នៃស្ត្រីអាយុចាប់ពី១៨ ដល់ ២៤ ឆ្នាំ បានរាយការណ៍ថាធ្លាប់ទទួលបានសារជាអក្សរ រូបភាព វីដេអូ ឬសំណើបែបផ្លូវភេទ ទាំងដែលពួកគេមិនបានស្នើសុំ និង/ឬដោយសារការលួចហែកចូលគណនេយ្យហ្វេសប៊ុក។[15] ការសិក្សានេះក៏បានរកឃើញដែរថាការរើសអើងតាមប្រព័ន្ធអនឡាញទៅលើក្រុមអ្នកស្រឡាញ់ភេទដូចគ្នា មានលក្ខណៈធម្មតា ក្នុងនោះ ២៣%នៃក្រុមអ្នកស្រឡាញ់ភេទដូចគ្នាដែលចូលរួមការស្ទង់មតិនេះ បានរាយការណ៍ថាពួកគេធ្លាប់ទទួលរងការរើសអើងតាមប្រព័ន្ធអនឡាញ និងក្នុងចំណោមនោះ ៩៣% ធ្លាប់ទទួលរងអំពើនៃការរើសអើងជាច្រើនសកម្មភាពតាមប្រព័ន្ធអនឡាញ។

ការបៀតបៀន និងការរើសអើងប្រឆាំងនឹងកុមារី ស្ត្រី និងបុគ្គលមិនកំណត់អត្តសញ្ញាណយេនឌ័រណាមួយតាមប្រព័ន្ធឌីជីថល កំពុងជួបការលំបាកក្នុងការបញ្ឈប់ និងមិនអាចរាយការណ៍អំពើទាំងនេះបានដោយងាយស្រួលដោយសារតែកង្វះវិធានការការពាររឹងមាំ។ ថ្វីត្បិតតែមានចំណុចវិជ្ជមានដែលធ្វើឡើងដោយរាជរដ្ឋាភិបាលកម្ពុជាដោយមានក្រសួងកិច្ចការនារី បានដឹកនាំសិក្ខាសាលាមួយចំនួននៅអំឡុងឆ្នាំ២០២១ ដើម្បីបង្ហាញពីគ្រោះថ្នាក់នៃការបៀតបៀនតាមប្រព័ន្ធអនឡាញដល់យុវជន និងដើម្បីបង្រៀនពីបច្ចេកទេសការពារក៏ដោយ ក៏វាជាការចាំបាច់ដែលរដ្ឋាភិបាលកម្ពុជាគួរចាប់ផ្តើមជំហានចាំបាច់ និងបន្ទាន់សម្រាប់ធ្វើការត្រួតពិនិត្យស្ថានភាពនេះឱ្យបានហ្មត់ចត់។ ក្រៅពីនេះ ក្រុមហ៊ុនដែលផ្តល់សេវាប្រព័ន្ធផ្សព្វផ្សាយសង្គម ត្រូវប្រើជំនាញបច្ចេកទេសនានា និងធនធាន

---

[15] The Cambodian League for the Promotion and Defense of Human Rights (*LICADHO*): Status Update Harassment on Social Media in Cambodia, November 2021

ហរិញ្ញវត្ថុដើម្បីបញ្ចូលសេរីភាពតាមប្រព័ន្ធអនឡាញសម្រាប់កុមារី និងស្ត្រីវ័យក្មេង ព្រមទាំងបុគ្គលមិនកំណត់អត្តសញ្ញាណយេនឌ័រ ទៅក្នុងចំណុចសំខាន់នៃរបៀបវារៈរបស់ខ្លួន។

### ៥) ការប្រើប្រាស់មិនត្រឹមត្រូវនូវការដោះស្រាយជម្លោះតាមវិធីសាស្ត្រផ្សេងៗក្នុងករណីអំពើហិង្សាផ្អែកលើយេនឌ័រ

ស្ត្រីកម្ពុជា ពិសេសស្ត្រីដែលរស់នៅទីជនបទ និង/ឬ ស្ថិតនៅក្នុងក្រុមជនជាតិភាគតិច និងក្រុមជនជាតិដើមភាគតិចប្រឈមនឹងឧបសគ្គកាន់តែខ្លាំងក្នុងការប្រើប្រាស់ប្រព័ន្ធយុត្តិធម៌ផ្លូវការ ដោយសារតែគម្លាតតំបន់ភូមិសាស្ត្រ ថ្លៃចំណាយខាងផ្នែកសេដ្ឋកិច្ច ការទទួលរងស្លាកស្នាមមិនល្អពីសង្គម ភ័យខ្លាចបែកខ្ញែកខ្វាយករណីរបស់ខ្លួនឱ្យគេដឹង ភ័យខ្លាចការសងសឹង ខ្វះការទទួលបានពត៌មាន និងសេវាផ្នែកច្បាប់នានា។[16] ដូច្នេះ ការដោះស្រាយជម្លោះតាមជម្រើសផ្សេងៗ (ADR) នៅបន្តជាជម្រើសរបស់ស្ត្រី និងអាជ្ញាធរមូលដ្ឋាន នៅក្នុងការដោះស្រាយទម្រង់ជាច្រើននៃករណីអំពើហិង្សាក្នុងគ្រួសារ។

ទោះជាយ៉ាងនេះក្តី យោងតាមការសិក្សាឆ្នាំ២០២០ អំពីការដោះស្រាយជម្លោះតាមជម្រើសផ្សេងៗ មានចំណងជើងថា "ការរក្សាភាពសុខដុមរមនា ឬការរក្សាយុត្តិធម៌" ជាការសិក្សាមួយស្តីអំពីការអនុវត្តនៃការដោះស្រាយជម្លោះតាមមូលដ្ឋាននៅក្នុងករណីមានអំពើហិង្សាក្នុងគ្រួសារ និងអំពើហិង្សាលើដៃគូស្និតស្នាល នៅកម្ពុជា ដែលបានបង្ហាញថា មានត្រឹមប្រហែល ២០%នៃអ្នកដែលបានស្វែងរកជំនួយពីការដោះស្រាយជម្លោះតាមជម្រើសផ្សេងៗ និងបានចូលរួមក្នុងការសិក្សានេះ បានឱ្យដឹងថាពួកគេទទួលបានបទពិសោធនវិជ្ជមាន ចំណែកឯ ៨០% ដែលនៅសល់នៃចំនួនអ្នកចូលរួមទាំងនេះបានឱ្យដឹងថា ពួកគេទទួលបានបទពិសោធន៍អវិជ្ជមាន។ បទពិសោធន៍អវិជ្ជមានទាំងនេះ គឺភាគច្រើនដោយសារភាពបរាជ័យរបស់អាជ្ញាធរក្នុងការបញ្ជូនករណីទាំងនេះសម្រាប់ធ្វើការស៊ើបអង្កេតបន្ថែមទៀត និងធ្វើការចោទប្រកាន់បើទោះបីជាអំពើហិង្សាមានសភាពធ្ងន់ធ្ងរ និង/ឬមានការស្នើសុំរបស់អ្នកនៅរស់រានមានជីវិតពីអំពើហិង្សា ដោយសារការបដិសេធមិនដំណើរការបណ្តឹងព្រហ្មទណ្ឌ ដោយសារក្រុមអ្នកមានឥទ្ធិពលនៅសហគមន៍ ដោយសារការស្តីបន្ទោសជនរងគ្រោះ និងការទទួលរងស្លាកស្នាមមិនល្អសម្រាប់ជនរងគ្រោះ ដោយសារការបន្តប្រើការដោះស្រាយជម្លោះតាមជម្រើសផ្សេងៗបើទោះជាមានភាពបរាជ័យម្តងហើយម្តងទៀតក៏ដោយ និងដោយសារបញ្ហានានាពាក់ព័ន្ធនឹងការលែងលះ។[17] ការសិក្សានេះ ក៏បានរកឃើញដែរថា ទម្រង់នៃការអនុវត្តការដោះស្រាយជម្លោះតាមជម្រើសផ្សេងៗនៅតាមមូលដ្ឋាន មិនមានលក្ខណៈគិតគូពីយេនឌ័រ និងមិនអនុវត្តតាមវិធីសាស្ត្រដែលផ្តោតសំខាន់លើអ្នកនៅរស់រានមានជីវិពីអំពើហិង្សាទេ ។ វិធីសាស្ត្រដោះស្រាយជម្លោះតាមជម្រើសផ្សេងៗ ជារឿយៗត្រូវបានប្រើជំនួសឱ្យការផ្សះផ្សា និងការសម្រុះសម្រួល ឬជំនួសឱ្យនីតិវិធីអាជ្ញាកណ្តាល ហើយក៏មិនស្របតាមគោលការណ៍សម្រុះសម្រួលតាមបែបទំនើបទេ ដែលជារឿយៗមិនអាចបម្រើផលប្រយោជន៍ល្អបំផុតរបស់ស្ត្រីទេ និង/ឬ មិនអាចការពារសុវត្ថិភាព និងសន្តិសុខរបស់ពួកគេបានដែរ។

---

[16] Ministry of Women's Affairs (MoWA). 2021. Final draft on Guidelines on the Limited Use of Mediation as a Response to Violence Against Women, p. 5. Adopted by the Technical Working Group on Gender based Violence on July 29th, 2021.

[17] Kry, S., Seewald, K., Sok, L., Meas, S., & Oy, M. (November 2020). *Preserving harmony, or preventing justice? A study of local dispute resolution practices in cases of intimate partner violence in Cambodia*. Phnom Penh: Women Peace Makers.

ដើម្បីជាការឆ្លើយតបនឹងបញ្ហាដែលបានលើកឡើងខាងលើ ព្រមទាំងដើម្បីដោះស្រាយនូវសេចក្តីកង្វល់ដែលបានលើកឡើងដោយសេចក្តីសង្កេតសន្និដ្ឋាននៃគណៈកម្មាធិការស៊ី-ដ ឆ្នាំ២០២១ ក្រសួងកិច្ចការនារី បានគាំទ្រដល់សេចក្តីព្រាង "គោលការណ៍ណែនាំអំពីកម្រិតនៃការប្រើប្រាស់ការសម្រុះសម្រួល ដើម្បីជាការឆ្លើយតបនឹងនឹងអំពើហិង្សាលើស្ត្រី"។ សមាជិកនៃក្រុមការងារបច្ចេកទេសខាងយេនឌ័រ និងអំពើហិង្សាផ្អែកលើយេនឌ័រ បានបោះឆ្នោតគាំទ្រឱ្យអនុម័តគោលការណ៍ទាំងនេះនៅអំឡុងកិច្ចប្រជុំលើទី ២៤នៃសមាជិកនៃក្រុមការងារបច្ចេកទេសខាងយេនឌ័រ និងអំពើហិង្សាផ្អែកលើយេនឌ័រ កាលពីថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២១។ គោលការណ៍ទាំងនេះ "ផ្តល់នូវនីតិវិធីនានាដើម្បីធានាថា ការសម្រុះសម្រួល មិនត្រូវបានប្រើក្នុងភាពមិនត្រឹមត្រូវ ដែលជាយន្តការជំនួសមួយដើម្បីបន្តឱ្យមាននិទ្ទណ្ឌភាពដល់ជនល្មើសនៃអំពើហិង្សាលើស្ត្រី [...] ការសម្រុះសម្រួល ត្រូវបានអនុញ្ញាតឱ្យប្រើតែនៅក្នុងករណីនៃបទឧក្រិដ្ឋស្រាលៗ និងក្នុងករណីនៃជម្លោះរដ្ឋប្បវេណីប៉ុណ្ណោះ [...] និងត្រូវធានាឱ្យបាននូវសុវត្ថិភាព សមធម៌ និងសមភាព ព្រមទាំងវិធីសាស្ត្រផ្តោតលើអ្នកនៅរស់រានមានជីវិតពីអំពើហិង្សា។[18] " ថ្វីត្បិតតែការអនុម័តគោលការណ៍ទាំងនេះ ជាជំហានវិជ្ជមានក្នុងការដោះស្រាយបញ្ហាក៏ដោយ ក៏អង្គការសង្គមស៊ីវិលនៅតែមានក្តីកង្វល់ថា ខ្លឹមសារពាក្យពេចន៍នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ នៅតែជំរុញឱ្យមានការប្រើប្រាស់នូវការសម្រុះសម្រួលក្រៅផ្លូវការស្ទើគ្រប់ករណីនៃអំពើហិង្សាក្នុងគ្រួសារ ដែលមិនស្របទៅតាមគោលការណ៍ទាំងនេះ និងអនុសញ្ញាស៊ី-ដ។ ការធ្វើវិសោធនកម្មនៃច្បាប់នេះចាំបាច់ត្រូវធ្វើឡើងឱ្យបានឆាប់រហ័ស។

រាជរដ្ឋាភិបាលត្រូវបង្កើត និងផ្សព្វផ្សាយនូវនីតិវិធីជាក់លាក់ និងងាយស្រួលអនុវត្តតាមសម្រាប់ដីកាការពារដែលចេញដោយតុលាការ និងដំណើរការស្របគ្នានៃសេចក្តីសម្រេចរដ្ឋបាលដែលចេញដោយសាលាឃុំជាបន្ទាន់។ ជាង ៧៨%នៃអ្នកប្រើប្រាស់សេវាជាស្ត្រីនៅក្នុងការសិក្សាលើកមុន បានបង្ហាញថា ពួកគេមិនដែលធ្លាប់ដឹងពីដីកាការពារ ឬសេចក្តីសម្រេចរដ្ឋបាលឡើយ ខណៈដែល ២២%ទៀតដែលនៅសល់ ធ្លាប់បានលឺពីដីកាការពារ និងសេចក្តីសម្រេចរដ្ឋបាលនេះ ក៏ប៉ុន្តែពួកគេមិនបានដឹងពីរបៀបក្នុងការទទួលបានវានោះទេ។ភាគច្រើននៃអាជ្ញាធរដែលជាអ្នកផ្តល់សេវានៅមូលដ្ឋានក៏បានបង្ហាញពីកង្វះខាតធ្ងន់ធ្ងរខាងផ្នែកចំណេះដឹង និងជំនាញអំពីសេវាដ៏សំខាន់នេះដែរសម្រាប់ធ្វើការឆ្លើយតបទៅនឹងអំពើហិង្សាងផ្អែកលើយេនឌ័រ។

បន្ថែមពីលើនេះទៀត ជម្រកសុវត្ថិភាព និងសេវាគាំទ្រផ្សេងទៀតដល់អ្នកនៅរស់រានមានជីវិតពីអំពើហិង្សាមានលេខទូរសព្ទទំនាក់ទំនងបន្ទាន់ថ្នាក់ជាតិ សម្រាប់ករណីអំពើហិង្សាផ្អែកលើយេនឌ័រ និងការទទួលបានជំនួយហិរញ្ញវត្ថុ ជំនួយផ្នែកច្បាប់ ការប្រឹក្សាយោបល់ផ្នែកផ្លូវចិត្ត និងផ្លូវច្បាប់ គួរត្រូវបានជំរុញជាបន្ទាន់ឱ្យមានសេវាទាំងនេះនៅទូទាំងប្រទេស និងដោយមិនគិតថ្លៃ។ លេខទូរសព្ទទំនាក់ទំនងបន្ទាន់ពីមុនសម្រាប់ករណីនៃអំពើហិង្សាផ្អែកលើយេនឌ័រ ត្រូវបានផ្ទេរទាំងស្រុងទៅឱ្យលេខទូរសព្ទទំនាក់ទំនងសុំជំនួយផ្នែកកុមារ (Child Helpline) ដែល

[18] Ibid. [Footnote #10]

ត្រឹមតែអាចជួយអ្នកនៅនៅរស់រានមានជីវិតពីអំពើហិង្សាដែលមានអាយុពេញវ័យតាមរយៈការណែនាំឱ្យទៅរកអង្គការសង្គមស៊ីវិលនៅតាមតំបន់ភូមិសាស្ត្រមួយចំនួនដោយមានកំណត់តែប៉ុណ្ណោះ។

ទោះជាយ៉ាងណាក្តី ដើម្បីធានាបានថាករណីនៃអំពើហិង្សាផ្អែកលើយេនឌ័រនឹងត្រូវបានដោះស្រាយជាប្រចាំទៅតាមវិធីសាស្ត្រដែលមានលក្ខណៈគិតគូពីយេនឌ័រ គិតគូពីសិទ្ធិ និងគិតគូពីអ្នកនៅរស់រានមានជីវិត លុះណាតែមានការធ្វើវិសោធនកម្មច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងការអនុវត្តប្រកបដោយប្រសិទ្ធភាពនៃច្បាប់នេះ ដោយរួមទាំងសេវា និងហេដ្ឋារចនាសម្ព័ន្ធដែលមានលក្ខណៈគិតគូពីយេនឌ័រ។ ការប្រើប្រាស់មិនត្រឹមត្រូវជាលក្ខណៈប្រព័ន្ធនៃវិធីសាស្ត្រដោះស្រាយជម្លោះតាមជម្រើសផ្សេងៗនៅតាមមូលដ្ឋានដែលមិនអនុលោមតាមបទដ្ឋានអន្តរជាតិនោះនឹងនៅតែបន្ត។ ដូច្នេះរាជរដ្ឋាភិបាលត្រូវចាត់វិធានការឱ្យបានកាន់តែឆាប់ក្នុងការបង្កើត និងអនុវត្តនូវផែនការច្បាស់លាស់មួយដើម្បីធ្វើវិសោធនកម្ម និងអនុវត្តក្រកបដោយប្រសិទ្ធភាពនូវច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ដែលខចែងមួយចំនួននៃច្បាប់នេះមានលក្ខណៈចម្រូងចម្រាសនិងមិនស្របគ្នា។ ឧទាហរណ៍ ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ បានចែងថាការសម្រុះសម្រួលអាចធ្វើទៅបានសម្រាប់តែករណីនៃបទឧក្រិដ្ឋស្រាលៗ ក៏ប៉ុន្តែនៅក្នុងក្រមព្រហ្មទណ្ឌ មិនបានបែងចែងប្រភេទនៃបទឧក្រិដ្ឋទៅជា "លក្ខណៈស្រាល" ឬ "ធ្ងន់"នោះទេ។ ម្យ៉ាងទៀត ដើម្បីធានាថា គោលការណ៍ទាំងនេះត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាពនោះ រាជរដ្ឋាភិបាលត្រូវបង្កើនទាំងកិច្ចប្រឹងប្រែង បង្កើនទាំងធនធាន និងសកម្មភាពថែមទៀត សម្រាប់ធ្វើការពង្រឹង និងកែលម្អការយល់ដឹង និងការអនុវត្តនៃសេវាហេដ្ឋារចនាសម្ព័ន្ធនានាដែលមានលក្ខណៈកាន់តែគិតគូពីយេនឌ័រនៅតាមមូលដ្ឋាន។

### ៦) ភាពជាអាជ្ញាកណ្តាលនៅក្នុងការអនុវត្តច្បាប់ក្នុងករណីអំពើហិង្សាផ្អែកលើយេនឌ័រ

ថ្វីត្បិតតែប្រទេសកម្ពុជាមានច្បាប់មួយចំនួន[19] ដែលដាក់ទោសនិងឆ្លើយតបទៅនឹងអំពើហិង្សាលើកុមារី និងស្ត្រី ក៏ដោយក៏ស្ត្រីនៅបន្តទទួលរងអំពើហិង្សានៅក្នុងអត្រាខ្ពស់មួយ ហើយមានករណីមួយចំនួនតូចប៉ុណ្ណោះដែលធ្លាប់នាំយកមកកាត់ទោស។ ការទទួលបានយុត្តិធម៌របស់ស្ត្រីកម្ពុជានៅមានកម្រិតនៅឡើយ ដោយសារការយល់មិនបានត្រឹមត្រូវអំពីសិទ្ធិ និងសេរីភាពផ្ទាល់ខ្លួនរបស់ពួកគេ ការទទួលរងស្លាកស្នាមមិនល្អ មិនមានឯករាជ្យភាពហិរញ្ញវត្ថុពីជនល្មើសនៃអំពើហិង្សា និងខ្វះពត៌មានអំពីសេវានានាដោយមិនគិតថ្លៃ ឬមានតម្លៃទាប។ ករណីនៃអំពើហិង្សាផ្អែកលើយេនឌ័រ ដែលមានកម្រិតខ្ពស់នោះ គឺត្រូវបានប្រព្រឹត្តដោយអាជ្ញាធរ និង/ឬ បុគ្គលដែលមានឥទ្ធិពល ដែលបានលើកឡើងនៅក្នុងរបាយការណ៍ត្រួតពិនិត្យលើការអនុវត្តអនុសញ្ញាស៊ី-ដ ប្រចាំឆ្នាំ២០២០ ហើយករណីនេះនៅតែមិនទាន់ត្រូវបានកាត់ទោសនៅឡើយទេ។ ពុំមានសកម្មភាពផ្លូវច្បាប់ណាត្រូវបានបង្កើតឡើង

[19] Law on the prevention of domestic violence and protection of victims (2005); the Criminal Code, the Criminal Procedure Code, and the Law on the Suppression of Human Trafficking and Sexual Exploitation (2008). These laws spell out the different types of violence that are criminalized under Cambodian law, sentencing (what the punishment is for committing these crimes) and procedure (how the justice system works to ensure fair treatment and access to justice under the law for everyone involved).

ដើម្បីប្រឆាំងនឹង ឧកញ៉ា ហេង ស៊ា អតីត ឧកញ៉ា ខួង ឆាយ និង លោក អ៊ុក កុសល អតីតស្នងការប៉ូលីសថ្នាក់ខេត្ត នៃខេត្តកំពង់ធំ ឡើយ។

ក្រសួងមហាផ្ទៃ បានអះអាងនៅក្នុងសេចក្តីថ្លែងការណ៍ដែលចេញផ្សាយក្នុងឆ្នាំ២០២១[20] ថាខ្លួនបានដោះស្រាយករណីចំនួន ២៩៤០ ដែលក្នុងនោះមានមនុស្សពាក់ព័ន្ធចំនួន៤២៧៦ នាក់ និងបានដាក់ពិន័យលើមន្ត្រីប៉ូលីសចំនួន ២៥៦ នាក់ ក្នុងនោះ ១២៣នាក់ក្នុងចំណោមពួកគេ ត្រូវបានបណ្តេញចេញពីកងកម្លាំង។ ទោះជាយ៉ាងនេះក្តី ក្រសួងមហាផ្ទៃមិនអាចផ្តល់ពត៌មានអំពីប្រភេទនៃករណីទាំងនោះទេ ដូច្នេះ យើងមិនបានដឹងថាតើមានចំនួនប៉ុន្មាននៃករណីទាំងនោះដែលពាក់ព័ន្ធនឹងអំពើហិង្សាផ្អែកលើយេនឌ័រ។ ដូចគ្នានេះដែរ ពុំមានពត៌មានបង្ហាញថាតើករណីទាំងនោះត្រូវបានដោះស្រាយតាមរយៈយន្តការនៃការដោះស្រាយជម្លោះតាមជម្រើសផ្សេងៗ ឬយ៉ាងណាឬមួយក៏តាមរយៈប្រព័ន្ធយុត្តិធម៌ផ្លូវការ។

ក្តីកង្វល់មួយដែលអង្គការសង្គមស៊ីវិលបានលើកឡើងនោះគឺ តម្រូវការនៃការធ្វើវិសោធនកម្ម និងការអនុវត្តច្បាប់នានាដែលមានគោលបំណងលុបបំបាត់អំពើហិង្សាលើដៃគូស្និតស្នាល អំពើហិង្សាផ្លូវភេទលើកុមារី និងគ្រប់ទម្រង់ផ្សេងទៀតនៃអំពើហិង្សាផ្អែកលើយេនឌ័រ ជាពិសេសនោះធ្វើការផ្តល់សេវានានាដែលបង្ហាញឱ្យឃើញនូវប្រសិទ្ធភាព ដែលផ្តោតលើសុខមាលភាពផ្លូវកាយ និងផ្លូវចិត្តរបស់អ្នកនៅរស់រានមានជីវិតពីអំពើហិង្សា ហើយធានានូវការទទួលបានយុត្តិធម៌ដល់អ្នកនៅរស់រានមានជិវិតពីអំពើហិង្សា។ បើទោះជាគ្មានការវិវឌ្ឍន៍ណាមួយត្រូវបានធ្វើឡើងដើម្បីធ្វើវិសោធនកម្មច្បាប់ណាមួយក៏ដោយ ក៏រដ្ឋាភិបាលបានបោះជំហានវិជ្ជមានដើម្បីឈានទៅកាត់បន្ថយការប្រើប្រាស់ការផ្សះផ្សា ដោយងាកមកគាំទ្រការសម្រុះសម្រួលប្រកបដោយវិជ្ជាជីវៈវិញ។ គោលការណ៍ណែនាំថ្មីស្តីអំពីការកម្រិតការប្រើប្រាស់ការសម្រុះសម្រួល ឆ្លើយតបចំពោះអំពើហិង្សាលើស្ត្រី ត្រូវបានអនុម័តរួចហើយដើម្បីជំរុញឱ្យអាជ្ញាធរមូលដ្ឋានប្រើប្រាស់វិធីសាស្ត្រដែលផ្តោតសំខាន់លើអ្នកនៅរស់រានមានជិវិតពីអំពើហិង្សា និងអនុវត្តការត្រួតពិនិត្យហ្មត់ចត់មុននឹងអនុវត្តការសម្រុះសម្រួល ដើម្បីធានាថាគ្មានកុមារ ឬស្ត្រីណាមួយស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ ឬត្រូវបានបំផិតបំភ័យឱ្យចូលរួមក្នុងដំណើរការសម្រុះសម្រួលនោះឡើយ។ គោលការណ៍ណែនាំនេះបានចែងថា ទម្រង់ណាមួយនៃការដោះស្រាយជម្លោះតាមជម្រើសផ្សេងៗ គួរត្រូវធ្វើឡើងដោយអ្នកសម្រុះសម្រួលប្រកបដោយវិជ្ជាជីវៈ និងមិនលម្អៀងប៉ុណ្ណោះ ហើយករណីណាដែលមិនអាចសម្រុះសម្រួលដោយសុវត្ថិភាពបាន គួរត្រូវបញ្ជូនទៅព្រះរាជអាជ្ញា និង/ឬ ស្នើសុំការចេញនូវសេចក្តីសម្រេចរដ្ឋបាល ឬដីកាការពារពីតុលាការ។

[20] Ministry of Interior (2021). Information Announcement on the Implementation of the MoI's Duty #002.Sor.Bror.Kor, May 2021

## ការងារ

### ១) ការរើសអើងក្នុងវិស័យសារពត៌មាន

នៅក្នុងឆ្នាំ២០២១ អ្នកសារពត៌មានជាស្ត្រី បានចេញនូវសេចក្តីថ្លៃការណ៍ជាសាធារណៈអំពីការប្រឈមនឹងការរើសអើងផ្អែកលើយេនឌ័រដែលកំពុងកើតមានឡើង និងការបៀតបៀនផ្លូវភេទនៅកន្លែងការងាររបស់ពួកគេព្រមទាំងនៅកន្លែងគោលដៅដែលពួកគេចុះទៅ។[21] ការសិក្សាស្រាវជ្រាវពីមុនដែលធ្វើឡើងដោយសហព័ន្ធអ្នកសារពត៌មានអន្តរជាតិ (IFJ) បានបង្ហាញពី ទំហំនៃការរើសអើង។[22] ស្ត្រីធ្វើការក្នុងប្រព័ន្ធផ្សព្វផ្សាយបានរាយការណ៍ថា ពួកគេទទួលរងសម្ពាធពីក្រុមគ្រួសារដើម្បីឱ្យលាឈប់ពីវិជ្ជាជីវៈរបស់ពួកគេ ដោយសារតែបទដ្ឋានឌ័រមានលក្ខណៈតឹងរឹង ដោយកំណត់ថាការងារជាអ្នកសារពត៌មាន គឺជាការងារសម្រាប់បុរស។[23] ទន្ទឹមនឹងការបៀតបៀតផ្លូវភេទបានកើតមានច្រើននៅកន្លែងធ្វើការ ប្រព័ន្ធផ្សព្វផ្សាយពិតមានភាគច្រើនមិនមានយន្តការផ្លូវការណាមួយនិង/ឬ គោលនយោបាយប្រឆាំងការបៀតបៀនផ្លូវភេទឡើយ គិតត្រឹមឆ្នាំ ២០១៥ ។ កត្តានេះ រឹតតែធ្វើឱ្យពិបាកដល់អ្នករងគ្រោះក្នុងការស្វែងរកការកែប្រែស្ថានការណ៍ និងយុត្តិធម៌ ហើយវាបានបន្ថែមលើឧបសគ្គដែលមានស្រាប់នានាដែលបង្កដោយការទទួលរងស្លាកស្នាមមិនល្អ និងភាពភ័យខ្លាចនៃការសងសឹក។[24]សហព័ន្ធអ្នកសារពត៌មានអន្តរជាតិ ក៏បានរកឃើញផងដែរថា គម្លាតដ៏ធំនៃប្រាក់កម្រៃយេនឌ័រដែលបានកើតមានឡើងនៅក្នុងវិស័យសារពិតមាន។ "ជាទូទៅ ស្ត្រីជាង ៨៨.៨៨% ទទួលបានប្រាក់កម្រៃប្រចាំខែពីចន្លោះ៨០ ទៅដល់ ២៥០ ដុល្លារអាមេរិក ធៀបនឹងបុរសមាន ៣៧.៧០% ដែលទទួលបានប្រាក់កម្រៃប្រចាំខែច្រើនជាង ៨០០ ដុល្លារអាមេរិក នេះមានន័យថាគម្លាតនៃការទទួលបានប្រាក់កម្រៃ គឺយ៉ាងតិច ៥៥០ ដុល្លារអាមេរិក [...]" ។

ប្រព័ន្ធផ្សព្វផ្សាយ បានអនុវត្តជាទូទៅមួយ ដែលធ្វើអោយ ពិតមានអំពីអំពីករណីអំពើហិង្សាផ្អែកលើយេនឌ័រល្បីខ្ទរខ្ទា ហើយចាត់ទុកករណីទាំងនេះជាការកំសាន្តចំពោះអ្នកអាន/អ្នកទស្សនាទៅវិញ ជាជាងការបង្ហាញពីភាពយល់ចិត្តអាណិតអាសូរចំពោះអ្នកនៅរស់រានមានជីវិតពីអំពើហិង្សា។ ខ្លឹមសារពាក្យពេចន៍មានលក្ខណៈប្រកាន់រើសអើងផ្អែកលើយេនឌ័រ ការបង្ហាញដែលមិនចាំបាច់នូវរូបភាព និង/ឬ អត្តសញ្ញាណនៃជនរងគ្រោះ/អ្នកនៅរស់រានមានជីវិត និងការរៀបរាប់លំអិតអំពីភាពតក់ស្លុត ស្នាមរបួស និងសកម្មភាពស្តែងៗនៃអំពើហិង្សា នៅតែត្រូវបានប្រើជាទូទៅនៅពេលធ្វើការរាយការណ៍ពីករណីនៃអំពើហិង្សាផ្អែកលើយេនឌ័រ។ ក្នុងរយៈពេលជិតប្រាំឆ្នាំ ចាប់តាំងពីក្រសួងកិច្ចការនារី និងក្រសួងពត៌មានបានរួមគ្នាបង្កើតក្រមប្រតិបត្តិប្រព័ន្ធផ្សព្វផ្សាយកសម្រាប់រាយការណ៍

---

[21] https://vodenglish.news/opinion-womens-challenges-in-newsrooms-are-going-unreported/

[22] *Country Report: "Media and Gender in Cambodia" Part of the IFJ Media and Gender in Asia-Pacific Research Project* available at: https://www.ifj.org/actions/ifj-campaigns/charting-cambodias-declining-press-freedom.html?tx_wbresources_list%5Bresource%5D=550&cHash=49c39a4ff769425ef49ef3f9fee6b582 accessed in January 2021.

[23] Ibid.

[24] Ibid.

ព័តមានអំពើហិង្សាលើស្ត្រី[25] ហើយនិងការបង្កើតក្រុមការងាររបស់ក្រសួងកិច្ចការនារីសម្រាប់ធ្វើការត្រួតពិនិត្យលើប្រព័ន្ធផ្សព្វផ្សាយ អង្គការសង្គមស៊ីវិលបានសង្កេតឃើញថា មានឥទ្ធពលតិចតួចប៉ុណ្ណោះលើឥរិយាបថ និងអកប្បកិរិយានៃវិស័យនេះដើម្បីឱ្យមានការរាយការណ៍ប្រកបដោយក្រមសីលធមិពីករណីអំពើហិង្សាលើស្ត្រី និងកុមារី និងអំពើហិង្សាផ្អែកលើយេនឌ័រ។ ក្រសួងកិច្ចការនារី និងក្រសួងពត៌មាន គួរតែបង្កើតឡើងនូវផែនការច្បាស់លាស់មួយដែលមានការកំណត់ពេលសម្រេចជាក់លាក់ និងមានធនធានដែលបានត្រៀមទុក ដើម្បីកែលម្អសមត្ថភាពសម្រាប់ធ្វើការរាយការណ៍ពិតមានប្រកបដោយក្រមសីលធមិ។ ជាងនេះទៅទៀត រដ្ឋាភិបាល គួរចាត់វិធានការដាក់វិន័យរដ្ឋបាល និងដាក់ទោសទណ្ឌលើស្ថានីយផ្សាយពិតមានណាដែលរំលោភលើក្រមប្រតិបត្តិនេះ។

## ២) ការរើសអើងលើអ្នកធ្វើការនៅក្នុងសេវាកំសាន្ត

គិតត្រឹមឆ្នាំ ២០១៩ មានអ្នកធ្វើការងារក្នុងសេវាកំសាន្តប្រមាណ ៧០០០០ នាក់ ក្នុងនោះមានស្ត្រី ៧៥% ដែលធ្វើការជាអ្នកម៉ាស្សា អ្នកប្រកបរបរផ្លូវភេទ អ្នកធ្វើការនៅតាមភោជនីដ្ឋាន អ្នកផ្សព្វផ្សាយស្រាបៀរ ព្រមទាំងអ្នកដែលធ្វើការនៅក្នុងហាងខារ៉ាអូខេ សណ្ឋាគារ និងកាស៊ីណូ។[26] អ្នកធ្វើការងារក្នុងសេវាកំសាន្តទាំងនេះ ងាយនឹងទទួលរងការកេងប្រវ័ញ្ចកំលាំងពលកម្ម និងគ្រប់ទម្រង់នៃអំពើហិង្សាផ្អែកលើយេនឌ័រ ជាពិសេសនោះងាយនឹងទទួលរងការបៀតបៀនផ្លូវភេទ និងការរើសអើងផ្អែកលើការមានផ្ទៃពោះ។ ពួកគេជារឿយៗត្រូវបានដកចេញពីការទទួលបានគម្រោងនៃកិច្ចគាំពារសង្គមរបស់ប្រទេស ដោយសារតែពួកគេភាគច្រើនមិនបានចុះឈ្មោះជាមួយរបបសន្តិសុខសង្គម។ បន្ថែមពីលើនេះ អ្នកធ្វើការងារក្នុងសេវាកំសាន្តជួបបញ្ហាប្រឈមច្រើនក្នុងការប្រើប្រាស់សិទ្ធិសហជីពរបស់ខ្លួន។ បើទោះជាមានក្របខណ្ឌច្បាប់ រួមមាន គោលនយោបាយជាតិ ច្បាប់ ប្រកាស ដែលត្រូវបានដាក់ចេញដោយរាជរដ្ឋាភិបាល ជាពិសេសដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីកែលម្អលក្ខខណ្ឌការងារ និងការពារផលប្រយោជន៍សម្រាប់អ្នកធ្វើការងារទាំងនោះក៏ដោយ ក៏ការរើសអើងនៅតែបន្តកើតមាន។

ដូចដែលបានលើកឡើងខាងលើ ឧទាហរណ៍ដែលងាយនឹងកត់សម្គាល់បំផុតនៃការរើសអើងលើសហជីពនៅក្នុងវិស័យកំសាន្ត នៅក្នុងឆ្នាំ២០២១ នោះគឺ ការបណ្តេញចេញនូវសមាជិកសកម្ម និងថ្នាក់ដឹកនាំសហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរនៃក្រុមហ៊ុនណាហ្គាវើលដ៍ (LRSU)។ ក្រុមហ៊ុនណាហ្គាវើលដ៍ បានកាត់បន្ថយបុគ្គលិកចំនួន ១៣២៩ នៅពាក់កណ្តាលឆ្នាំ២០២១ ដោយលើកឡើងពីការខាត់បង់ប្រាក់ចំណូលដែលបណ្តាលមកពីផលប៉ះពាល់នៃវិបត្តិកូវីដ-១៩។ ក៏ប៉ុន្តែ បុគ្គលិកដែលត្រូវបានជ្រើសរើសក្នុងការកាត់បន្ថយ នោះ គឺជាថ្នាក់ដឹកនាំសហជីពជាស្ត្រី និងអ្នកដែលមានផ្ទៃពោះ និងទើបក្លាយជាម្តាយថ្មីៗ ដោយមិនមានលក្ខណៈសមាមាត្រ។ សហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរ បានធ្វើការតវ៉ាលើការសម្រេចបញ្ឈប់បុគ្គលិកនេះដោយនាំយកពាក្យបណ្តឹង

[25] Ministry of Women's Affairs and Ministry of Information (2017): Joint Prakas on Media Code of Conducts for Reporting Violence Against Women http://ngocedaw.org/wp-content/uploads/2014/10/Media-Code-of-Conduct-for-Reporting-on-Violence-Against-Women-English-Translation.pdf

[26] Data from Oxfam and CFSWF in 2019. https://oi-files-cng-prod.s3.amazonaws.com/cambodia.oxfam.org/s3fs-public/file_attachments/Entertainment%20Workers.pdf

របស់ខ្លួនទៅក្រុមប្រឹក្សាអាជ្ញាកណ្តាលកម្ពុជា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងអង្គការអន្តរជាតិខាងផ្នែកការងារ (ILO) ប៉ុន្តែមិនទទួលបានលទ្ធផលពីការប្រឹងប្រែងរបស់ពួកគេនោះឡើយ។ បន្តក្រោយមកទៀត ពួកគេបានផ្តើមធ្វើកូដកម្មដោយសន្តិវិធី នៅក្នុងឆ្នាំ២០២១ ប៉ុន្តែបានទទួលរងបញ្ហាប្រឈមចំពោះសិទ្ធិរបស់ពួកគេក្នុងការធ្វើកូដកម្ម និងការចូលរួមសមាគមដោយសេរី ហើយពួកគេបានទទួលរងការប្រើប្រាស់អំពើហិង្សាដែលគាំទ្រដោយរដ្ឋ មានការបៀតបៀនផ្លូវភេទ និងការចាប់ខ្លួនដោយមិនត្រឹមត្រូវ។ ទន្ទឹមនឹងនេះ ថ្វីតែរដ្ឋាភិបាលបានបង្កើតនូវជំហានវិជ្ជមាននានាក្នុងការជ្រើសរើសកងកម្លាំងសន្តិសុខជាស្ត្រីក៏ដោយក៏អំពើហិង្សានៅតែបន្តកើតមាន ការណ៍នេះបង្ហាញថា មានការងារជាច្រើនទៀតដែលរដ្ឋាភិបាលចាំបាច់ត្រូវអនុវត្ត ដើម្បីធានាថាគ្រប់បុគ្គលិកសន្តិសុខត្រូវបានបណ្តុះបណ្តាលពេញលេញ ដូច្នេះនៅពេលមានការប្រមូលផ្តុំជាសាធារណៈ ពួកគេអាចធ្វើអន្តរកម្មក្នុងលក្ខណៈប្រកបដោយសុវត្ថិភាព សីលធម៌ និងគិតគូពីយេនឌ័រ។

### ៣) ការបៀតបៀនផ្លូវភេទ

ពុំមានការវិវឌ្ឍន៍ដ៏គួរឱ្យកត់សម្គាល់ណាមួយដើម្បីធ្វើឱ្យមានភាពច្បាស់លាស់លើច្បាប់នានាពាក់ព័ន្ធនឹងការបៀតបៀនផ្លូវភេទ ឬដើម្បីបង្កើតគោលការណ៍ណែនាំស្តីពីការបៀតបៀនផ្លូវភេទ ដែលត្រូវបានដាក់បញ្ចូលជាសកម្មភាពនៅក្នុងផែនការសកម្មភាពជាតិស្តីពីអំពើហិង្សាលើស្ត្រី (NAPVAW3) នោះទេ។

នៅក្នុងឆ្នាំ២០២១ អនុសញ្ញារបស់អង្គការពលកម្មអន្តរជាតិខាងផ្នែកការងារ (ILO) ដើម្បីលុបបំបាត់អំពើហិង្សាផ្អែកលើយេនឌ័រ និងការបៀតបៀននៅកន្លែងធ្វើការ (ILO C190) បានផ្តល់គោលការណ៍ណែនាំក្នុងការទប់ស្កាត់ និងលុបបំបាត់រាល់ការបៀតបៀន អំពើហិង្សា និងទម្រង់ផ្សេងទៀតនៃការរើសអើងផ្អែកលើយេនឌ័រនៅកន្លែងធ្វើការ បានចូលជាធរមានចំពោះប្រទេសដែលបានផ្តល់សច្ចាប័នដល់អនុសញ្ញានេះ។ យ៉ាងណាមិញ បើទោះបីជាមានការបោះឆ្នោតដោយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីគាំទ្រឱ្យអនុម័តអនុសញ្ញា ILO C190 តាំងពីអនុសញ្ញានេះត្រូវបានយល់ព្រមជាលើកដំបូងដោយ អង្គការ ILO ក៏ដោយ ក៏ពុំមានការវិវឌ្ឍន៍ណាមួយត្រូវបានធ្វើឡើងដើម្បីឈានទៅរកការផ្តល់សច្ចាប័នលើអនុសញ្ញានេះនៅឡើយ។

អង្គការសង្គមស៊ីវិល ដែលធ្វើការត្រួតពិនិត្យលើការវិវឌ្ឍន៍របស់ប្រទេសកម្ពុជាក្នុងការអនុវត្តសេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការស៊ី-ដ ចាប់តាំងពីឆ្នាំ ២០០១៩ មក ស្តីពីវិស័យការងារ បានសង្កេតឃើញថាមានការវិវឌ្ឍន៍តិចតួចណាស់លើអនុសាសន៍របស់គណៈកម្មាធិការស៊ី-ដ ដូចជា ការស្នើឱ្យផ្តល់សច្ចាប័នលើអនុសញ្ញា ILO C190 ជាដើម។ អង្គការសង្គមស៊ីវិល បានធ្វើយុទ្ធនាការជាបន្តបន្ទាប់ ដើម្បីជំរុញឱ្យមានការអនុវត្តនូវអនុសាសន៍ដែលស្នើឱ្យផ្តល់សច្ចាប័នលើអនុសញ្ញាលេខ ១៩០ របស់អង្គការពលកម្មអន្តរជាតិខាងផ្នែកការងារ ស្តីពីអំពើហិង្សានៅកន្លែងធ្វើការ ដែលនឹងក្លាយជាយន្តការមួយពាក់ព័ន្ធទៅនឹងការដោះស្រាយការបៀតបៀនផ្លូវភេទ និងផ្តល់រចនាសម្ព័ន្ធសម្រាប់បង្កើតគោលការណ៍ស្តីពីការបៀតបៀនផ្លូវភេទ ដែលបានស្នើឡើងដោយផែនការសកម្មភាពជាតិលើកទី ៣ដើម្បីទប់ស្កាត់អំពើហិង្សាលើស្ត្រី។

## សុខភាព

នៅក្នុងឆ្នាំ២០២១ ស្ត្រីបានប្រឈមផលប៉ះពាល់សុខភាពដោយមិនមានលក្ខណៈសមាមាត្រ ដោយសារការរីករាលដាលនៃជំងឺកូវីដ ១៩ នៅក្នុងសហគមន៍។ ការថែទាំសុខភាពរបស់ស្ត្រីបានប្រឈមនឹងឧបសគ្គនានានៅក្នុងរយៈពេលប៉ុន្មានខែកន្លងមកនេះ នៅពេលដែលរដ្ឋាភិបាលបានផ្តោតកិច្ចប្រឹងប្រែងរបស់ខ្លួនពាក់ព័ន្ធទៅលើសុខភាពក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ ១៩ ប៉ុន្តែការដែលធ្វើបែបនេះ ក៏បានបង្វែរធនធានមួយផ្នែកចេញពីការថែទាំសុខភាពរបស់ស្ត្រីផងដែរ។ ជាឧទាហរណ៍ កាលពីថ្ងៃទី២៧ ខែមីនា ឆ្នាំ ២០២១ មន្ទីរពេទ្យស្ត្រីឈ្មោះ នគរទេពដែលបានបើកដំណើរការនៅក្នុងឆ្នាំ២០១៩ ដើម្បីអាចឱ្យស្ត្រីដែលមានចំណូលទាបបានទទួលសេវាថែទាំសុខភាពបន្តពូជ[27] ត្រូវបានទិញយកដោយរដ្ឋាភិបាលសម្រាប់ប្រើក្នុងការព្យាបាលអ្នកជម្ងឺកូវីដ ១៩។ បើទោះជាម្ចាស់ដើមនៃមន្ទីរពេទ្យនេះ បានប្រកាសពីគោលបំណងរបស់ខ្លួនក្នុងការសាងសង់មន្ទីរពេទ្យថ្មីមួយទៀតក៏ដោយ ក៏លទ្ធផលចុងក្រោយ គឺស្ត្រីនឹងមិនទាន់អាចទទួលបានសេវាព្យាបាលខាងផ្នែកសុខភាពស្ត្រី ហើយត្រូវរងចាំក្នុងរយៈពេលបន្តទៅមុខទៀត។[28]

ផលប៉ះពាល់ដែលបណ្តាលមកពីការកាត់បន្ថយសេវាកម្មទាំងនេះ គឺការស្លាប់របស់ស្ត្រីមានផ្ទៃពោះដែលមានចំនួនមិនសមាមាត្រដោយសារជំងឺ កូវីដ ១៩ ។ មានស្ត្រីមានផ្ទៃពោះច្រើនជាង ៥៦០ នាក់បានស្លាប់ដោយសារភាពស្មុគស្មាញដែលបណ្តាលមកពីជំងឺ កូវីដ ១៩ គិតត្រឹមដើមខែ វិច្ឆិកា ឆ្នាំ២០២១ ដែលចំនួននេះស្មើនឹង ២០% នៃអាត្រាការស្លាប់ទាំងអស់នៃជំងឺកូវីដ ១៩។

ថ្វីត្បិតតែរដ្ឋាភិបាលបានបង្កើតយុទ្ធសាស្ត្រជាតិរយៈពេល ៥ ឆ្នាំ សម្រាប់សុខភាពផ្លូវភេទ និងសុខភាពបន្តពូជនៅកម្ពុជាសម្រាប់ឆ្នាំ ២០១៧-២០២០ ប៉ុន្តែមានទិន្នន័យតិចតួចប៉ុណ្ណោះដែលបង្ហាញជាសាធារណៈ អំពីការអនុវត្តដោយរដ្ឋាភិបាលលើផែនការនេះ ថាតើបានទទួលលទ្ធផលល្អកម្រិតណា។ មជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក (NMCHC) និង អង្គការ UNFPA បានបោះពុម្ពផ្សាយនូវរបាយការណ៍វាយតម្លៃមួយនៅក្នុងខែកក្កដា ឆ្នាំ ២០២១ ស្តីពីផលប៉ះពាល់នៃជំងឺកូវីដ-១៩ ទៅលើសុខភាពបន្តពូជ និងសុខភាពមាតា នៅក្នុងតំបន់ដែលទទួលរងការបិទខ្ទប់។[29] ដោយផ្អែកលើការសម្ភាស៍តាមទូរសព្ទនៅអំឡុងពេល និងក្រោយពីកាបិទខ្ទប់ភ្លាមៗ ការវាយតម្លៃនេះបានបង្ហាញថា សេវានានាត្រូវបានទទួលរងការរអាក់រអួល និងក៏មិនអាចត្រឡប់ទៅរកដំណើរការជាប្រក្រតីភ្លាមៗវិញបានដែរ។ បើទោះជាបុគ្គលិកផ្តល់សេវាមានបំណងផ្តល់សេវាថែទាំជាប្រចាំពីចម្ងាយដោយប្រើទូរសព្ទសម្រាប់ធ្វើការពិនិត្យក៏ដោយ ក៏បុគ្គលិកផ្នែកសុខភាពជាច្រើន ត្រូវបានបង្វែរពីការផ្តល់សេវាថែទាំសុខភាពផ្លូវភេទ និងសុខភាពបន្តពូជទៅជួយការងារផ្នែកទប់ស្កាត់ជំងឺកូវីដ ១៩ វិញ។

---

[27] https://www.khmertimeskh.com/50589884/nokor-tep-womens-hospital-launched-in-phnom-penh/
[28] https://www.phnompenhpost.com/national/covid-treatment-facilities-expand
[29] https://nmchc.gov.kh/en/final-report-of-rapid-assessment-of-srmh-under-covid-19/

នៅក្នុងសេចក្ដីអង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការស៊ី-ដនៅឆ្នាំ២០១៩សម្រាប់ប្រទេសកម្ពុជា បានបង្ហាញពីក្ដីកង្វល់អំពី "កម្រិតនៃការទទួលបានសេវាថែទាំសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ ព្រមទាំងពត៌មានដែលពាក់ព័ន្ធនានា រួមមាន វិធីសាស្ត្រពន្យារកំណើតបែបទំនើប និងការយកកូនចេញដោយសុវត្ថិភាព ជាពិសេសសម្រាប់ស្ត្រីដែលមិនទាន់រៀបការ និងក្មេងស្រី ព្រមទាំងក្ដីកង្វល់អំពីការទទួលរងស្លាកស្នាមមិនល្អរបស់ស្ត្រី និងក្មេងស្រី ដែលប្រើសេវាបែបនេះ ដែលបញ្ហានេះនាំឱ្យមានអត្រាខ្ពស់នៃចំនួនស្លាប់នៅពេលសម្រាល និងការមានផ្ទៃពោះមុនពេលកំណត់"។ គណៈកម្មាធិការ ស៊ី-ដ ក៏បានផ្ដល់អនុសាសន៍ដល់រាជរដ្ឋាភិបាលឱ្យពង្រឹងលទ្ធភាពនៃការទទួលបានសេវាថែទាំសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ រួមមាន សេវាយកកូនចេញដោយសុវត្ថិភាព ការថែទាំសុខភាពទាំងនៅពេលរំលូត និងក្រោយពេលរំលូត ការប្រឹក្សាយោបល់ដោយសម្ងាត់ និងការព្យាបាលជំងឺកាមរោគ និងជំងឺឆ្លងតាមផ្លូវភេទ (STI/STD) ។ គណៈកម្មាធិការ ស៊ី-ដក៏បានផ្ដល់អនុសាសន៍បន្ថែមទៀតដោយស្នើឱ្យរាជរដ្ឋាភិបាល "ប្រយុទ្ធប្រឆាំងនឹងការទទួលរងនូវស្លាកស្នាមមិនល្អរបស់កុមារី និងស្ត្រី ជាពិសេសអ្នកដែលមិនទាន់រៀបការ ដែលប្រើសេវាពន្យារកំណើត និងការយកកូនចេញដោយសុវត្ថិភាព ដោយតាមរយៈការអនុវត្តកម្មវិធីសិក្សានៅសាលាស្ដីពីចំណេះដឹងផ្លូវភេទឱ្យបានទូលំទូលាយ។[30]

សមាគមថែទាំសុខភាពគ្រួសារកម្ពុជា (RHAC) បានធ្វើការសិក្សាមួយនៅក្នុងឆ្នាំ ២០២១ ដើម្បីផ្ទៀងផ្ទាត់លើការសិក្សាមួយទៀតដែលបានធ្វើឡើងនៅក្នុងឆ្នាំ ២០១៩ " ការសិក្សាស្រាវជ្រាវបឋមថ្នាក់ជាតិ ស្ដីពីសិទ្ធិទទួលបានសេវានៃការយកកូនចេញដោយសុវត្ថិភាព" ដែលបានពិនិត្យលើការទទួលរងស្លាកស្នាមមិនល្អ និងការរើសអើងពាក់ព័ន្ធនឹងការយកកូនចេញនៅកម្ពុជា។ លទ្ធផលស្ទង់មតិនៅក្នុងឆ្នាំ២០១៩ ពីខេត្តកំពត និងសៀមរាប បានបង្ហាញថា នៅមានកម្រិយនៃការយល់ដឹងអំពីកិច្ចការពារផ្លូវច្បាប់សម្រាប់ការរំលូត គឺពាក់ព័ន្ធយ៉ាងជិតស្និតនឹងឧបសគ្គចំពោះការទទួលបានសេវានៃការរំលូតរបស់ស្ត្រី រួមមាន តម្លៃ ពេលវេលា ចម្ងាយផ្លូវ គុណភាពនៃការថែទាំ ការទទួលរងស្លាកស្នាមមិនល្អ និងការយល់ខុសពីភាពស្របច្បាប់នៃសេវានេះ។ ចំណែកឯលទ្ធផលស្ទង់មតិនៅក្នុងឆ្នាំ ២០២១ បានបង្ហាញពីការថយចុះនៃការទទួលរងស្លាកស្នាមមិនល្អពីសង្គម ក៏ប៉ុន្តែការទទួលរងស្លាកស្នាមមិនល្អពីសំណាក់បុគ្គលនៅតែមានសភាពធ្ងន់ធ្ងរខ្លាំង។ ការសិក្សានេះ បានលើកឡើងជាអនុសាសន៍ ឱ្យធ្វើការផ្ដល់អាទិភាពលើការបង្កើនជំនួយគាំទ្រ និងការតស៊ូមតិ ដើម្បីបង្កើនចំណេះដឹង និងការផ្លាស់ឥរិយាបថ។ នៅដំណាក់កាលបង្កើតគម្រោងនិងកម្មវិធី អ្នកផ្ដល់សេវាត្រូវពិចារណាលើតម្រូវការនៃអ្នកប្រើប្រាស់សេវា រួមមានស្ត្រី និងយុវវ័យ ដែលសមត្ថភាពនៅមានកម្រិតចំពោះការអាន និងសរសេរ និងតួនាទីនៃសម្ពាធសង្គមលើការទទួលរងស្លាកស្នាមមិនល្អ និងការរើសអើង ជាពិសេសប្រឈមដោយស្ត្រីមានផ្ទៃពោះដែលមិនបានរៀបការ។ ការផលិតសម្ភារៈអប់រំសម្រាប់ផ្ដល់ពត៌មាន គួរត្រូវបានបង្កើតឡើងជាមួយគោលបំណងធានានូវការទទួលបានដោយស្មើភាពគ្នាសម្រាប់គ្រប់ស្ត្រី និងក្រុមដែលមានសម្លេងភាគតិចទាំងអស់។

[30] CEDAW Concluding Observations, November 12, 2019, Paragraphs 38, 39

នៅអំឡុងឆ្នាំ ២០២១ មជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក បានធ្វើសេចក្តីព្រាងនៃការពង្រីកយុទ្ធសាស្ត្រជាតិដែលមានស្រាប់ក្នុងការផ្តល់សេវាថែទាំសុខភាពបន្តពូជ និងសុខភាពផ្លូវភេទ សម្រាប់ ឆ្នាំ២០២១-២០២៣ ក្នុងកិច្ចសហការជាមួយអង្គការ RHAC អង្គការUNFPA និងអង្គការ CHAI និងអ្នកដែលពាក់ព័ន្ធផ្សេងទៀត។ មតិយោបល់មួយពីអង្គការសង្គមស៊ីវិល គឺការដាក់បញ្ចូលផែនការដើម្បីកាត់បន្ថយការទទួលរងស្លាកស្នាមមិនល្អពីការរំលូត និងកែលម្អការផ្តល់សេវា ដោយបញ្ចូលនិងការបកស្រាយបំភ្លឺពីគុណតម្លៃនៃការរំលូត និងការផ្លាស់ប្តូរអកប្បកិរិយា (VCAT) ទៅក្នុងគោលការណ៍បណ្តុះបណ្តាលគ្រប់ជ្រុងជ្រោយអំពីការថែទាំសុខភាពនៅពេលរំលូត (CAC)។ លទ្ធផលជាវិជ្ជមានដ៏សំខាន់មួយនៃដំណើរការពិគ្រោះយោបល់នោះគឺ គោលបំណងដាក់បញ្ចូលការថែទាំសុខភាពផ្លូវភេទ និងសុខភាពបន្តពូជទៅក្នុងកម្មវិធីសិក្សាថ្នាក់ជាតិស្តីពី "ការអប់រំសុខភាព" របស់ក្រសួងអប់រំ យុវជន និងកីឡា។

នៅក្នុងឆ្នាំ ២០២១ អង្គការអប់រំសុខភាពគ្រួសារកម្ពុជា បានធ្វើការសិក្សាវាយតម្លៃផងដែរអំពី "ប្រសិទ្ធភាពនៃការប្រើប្រាស់ពិធីសារថ្នាក់ជាតិស្តីពី ការថែទាំសុខភាពសម្រាប់ស្ត្រីដែលទទួលរងអំពើហិង្សា" ដែលការសិក្សានេះបានរកឃើញថា ការយល់ដឹងនៅតែមានកម្រិតអំពីសុខភាព និងអំពើហិង្សាផ្អែកលើយេនឌ័រ របស់សហគមន៍ និងបុគ្គលិកផ្តល់សេវា ជាពិសេសអ្នកដែលមិនទទួលបានការបណ្តុះបណ្តាលជាក់លាក់អំពីពិធីសារនេះ ។ ផ្នត់គំនិតអវិជ្ជមាននៅតែបន្តកើតមាន ដែលបណ្តាលមកពីឧបសគ្គក្នុងការទទួលបានសេវាថែទាំសុខភាពបន្តពូជ និងពត៌មាន។ អ្នកប្រើប្រាស់សេវាដែលជាអ្នកនៅរស់រានមានជីវិតពីអំពើហិង្សា អាចនឹងមិនបានរៀបរាប់ពេញលេញពីអ្វីដែលពួកគេកំពុងទទួលរងនោះឡើយ ដោយសារការទទួលរងនូវស្លាកស្នាមមិនល្អ និងដោយសារពួកគេអាចនឹងមិនបានស្វែងរកការប្រឹក្សាយោបល់ ពីព្រោះពួកគេមានអារម្មណ៍ភ័យខ្លាចនឹងទទួលរងអំពើហិង្សា និងការសងសឹកបន្ថែមទៀត។ កត្តានានាដែលរួមចំណែកដល់ការបន្តកើតមាននូវអំពើហិង្សាលើស្ត្រី និងកុមារី និងបុគ្គលមិនកំណត់អត្តសញ្ញាណយេនឌ័រនោះមានដូចជា៖ អារម្មណ៍ភ័យតក់ស្លុត ការព្រួយបារម្ភពីសុវត្ថិភាព កង្វះការទទួលបានពត៌មានអំពីកិច្ចគាំពារសង្គម កង្វះសេវានានាដែលជួយគាំទ្រ និងពង្រឹងភាពមិនងាយចុះចាញ់ ក៏ដូចជាផ្នត់គំនិតពេបជ្រាយចំពោះភាពជាស្ត្រីមេម៉ាយ ឬស្ត្រីផ្សេងទៀតដែលធ្លាប់មានសកម្មភាពផ្លូវភេទពីមុនមក ។

## ការរើសអើងលើសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា ជាពិសេសការទទួលការថែទាំសុខភាព និងការងារ

នៅក្នុងកិច្ចប្រជុំត្រួតពិនិត្យឡើងវិញលើការអនុវត្តអនុសញ្ញា ស៊ី-ដ ឆ្នាំ២០១៩ អង្គការសង្គមស៊ីវិល បានគូសបញ្ជាក់ពីការកោតសរសើរដល់រាជរដ្ឋាភិបាលដែលបានបង្កើតអោយមានភាពរីកចម្រើនពាក់ព័ន្ធនឹងការលើកកម្ពស់ និងកិច្ចការពារនូវសិទ្ធិស្មើគ្នានៃក្រុមសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជា។ ឧទាហរណ៍ជាក់ស្តែង ក្រសួងអប់រំ យុវជន និងកីឡា ក្នុងកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលបានដាក់ឱ្យដំណើរការនូវកម្មវិធីអប់រំអំពីផ្លូវភេទដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយនៅក្នុងសាលារៀនលើមុខវិជ្ជា"ការអប់រំសុខភាព"។ កម្មវិធីសិក្សានេះសម្រាប់ថ្នាក់កម្រិតវិទ្យាល័យ ដោយបញ្ចូលនូវគោលគំនិតទាក់ទងនឹង និន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទ (SOGIESC) និងសិទ្ធិ រួមមានសិទ្ធិទទួលបានការ

ថែទាំសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ។ ក្រសួងកិច្ចការនារី បានកំណត់យកស្ត្រីដែលស្រឡាញ់ភេទដូចគ្នា ស្ត្រីដែលមានទំនោរផ្លូវភេទទាំងពីរ និងស្ត្រីដែលបានកែភេទ (LBT) ជាក្រុមគោលដៅអាទិភាពមួយនៅក្នុងផែនយុទ្ធសាស្ត្រនារីរតនៈ និងបានគូសបញ្ជាក់នៅក្នុងផែនការសកម្មភាពជាតិលើកទី៣ ដើម្បីទប់ស្កាត់អំពើហិង្សាលើស្ត្រី (ឆ្នាំ ២០១៩-២០២៣)ថាពួកគេស្ថិតក្នុងហានិភ័យប្រឈមនឹងអំពើហិង្សាកាន់តែច្រើន ។ បន្ថែមពីលើនេះទៀត ក្នុងកំឡុងនៃការប្រារព្វទិវានៃខែមោទនភាពក្នុងឆ្នាំ ២០២១ និងទិវាអន្តរជាតិបញ្ឈប់ការរើសអើងលើអ្នកស្រលាញ់ភេទដូចគ្នា (IDAHOTB) មន្ត្រីជាន់ខ្ពស់រាជរដ្ឋាភិបាលបានជំរុញលើកទឹកចិត្តជាសាធារណៈដល់សាធារណៈជនកុំឱ្យរើសអើងលើសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា។

បើទោះជាកិច្ចប្រឹងប្រែងទាំងនេះ ត្រូវបានចាត់ទុកជាជំហានវិជ្ជមានក៏ដោយ ក៏គួរពិនិត្យដោយយកចិត្តទុកដាក់លើកិច្ចប្រឹងប្រែងទាំងនេះ ដោយហេតុថារាជរដ្ឋាភិបាលកម្ពុជាពុំទាន់ចាត់វិធានការជាក់លាក់ និងគួរឱ្យកត់សម្គាល់ណាមួយនៅឡើយក្នុងការពន្លឿនដំណើរការកែទម្រង់ច្បាប់ដែលចាំបាច់ដល់ការប្រើប្រាស់ពេញលេញនូវសិទ្ធិរបស់អ្នកស្រលាញ់ភេទដូចគ្នា (SOGIESC) រួមមាន សិទ្ធិរៀបអាពាហ៍ពិពាហ៍ និងសិទ្ធិស្មើគ្នាក្នុងការទទួលកូនយកមកចិញ្ចឹមសម្រាប់ដៃគូដែលស្រឡាញ់ភេទដូចគ្នា។ បទដ្ឋានសង្គម និងការកំណត់តួនាទីយេនឌ័រដែលមានលក្ខណៈរើសអើងនៅតែបន្តកើតមានពាសពេញសង្គម និងការរើសអើងលើសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាគឺជារឿងធម្មតា ទាំងនៅក្នុងវិស័យឯកជន និងសាធារណៈ និងរួមទាំងវិស័យការងារផងដែរ។

## អនុសាសន៍របស់សង្គមស៊ីវិល ដើម្បីអនុវត្តកាន់តែប្រសើរនូវសេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការទទួលបន្ទុកលើអនុសញ្ញាស៊ីដ

អង្គការគណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ដើម្បីអនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ (NGO-CEDAW) និងអង្គការដៃគូរបស់ខ្លួន សូមសំណូមពរដល់រាជរដ្ឋាភិបាលចាត់នូវវិធានការ និងផ្តល់អាទិភាពក្នុងការអនុវត្តសកម្មភាពដូចខាងក្រោម ៖

១) យើងខ្ញុំសូមអំពាវនាវដល់រាជរដ្ឋាភិបាល សូមបង្កើតច្បាប់ប្រឆាំងនឹងការរើសអើងដែលមានលក្ខណៈពេញលេញដោយធានាអោយមានយន្តការច្បាប់មួយសម្រាប់អនុវត្តនូវសិទ្ធិរបស់ស្ត្រីនៅក្នុងរដ្ឋធម្មនុញ្ញ និងអនុសញ្ញាស៊ី-ដ និងលុបចោលនូវរាល់មាត្រាទាំងអស់នៅក្នុងច្បាប់ដែលចូលជាធរមានដែលមិនស្របគ្នាទៅនឹងសិទ្ធិទាំងនោះ។ យើងខ្ញុំសូមសំណូមពរដល់រដ្ឋាភិបាលឱដំណើរការការសិក្សាវិភាគជាប្រចាំអំពីយេនឌ័រនៅគ្រប់សេចក្តីព្រាងច្បាប់ ឬគោលនយោបាយនានា។

២) យើងខ្ញុំទាំងអស់គ្នានៅតែបន្តអំពាវនាវ សូមឱ្យមានការបម្រុងថវិកាជំនួយរយៈពេលវែងចេញពីថវិកាជាតិសម្រាប់អនុវត្តការងារបញ្ជ្រាបយេនឌ័រ ប្រយោជន៍បង្កើនសមភាពយេនឌ័រលើគ្រប់វិស័យ។

៣) យើងខ្ញុំសូមសំណូមពរឱមានកិច្ចប្រឹងប្រែងជាក់លាក់ ដើម្បីប្រយុទ្ធប្រឆាំងនឹងផ្នត់គំនិតដែលថាការសម្រុះសម្រួលក្នុងករណីនៃអំពើហិង្សាលើដៃគូស្និទ្ធិស្នាល គឺជាលទ្ធផលដែលសមស្រប។ រាជរដ្ឋាភិបាលចាំបាច់គួរតែធ្វើសកម្មភាពច្បាស់លាស់ក្នុងការធ្វើវិសោធន៍កម្ម និងពង្រឹងច្បាប់ស្តីពី « ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ » ដើម្បីឆ្លុះបញ្ចាំងថាសិទ្ធិនៃអ្នកនៅរស់រានជីវិតពីអំពើហិង្សាស្របតាមទៅតាមជម្រើសរបស់ពួកគេក្នុងការទទួលបានដំណោះស្រាយប្រកបដោយប្រសិទ្ធភាព និងយុត្តិធម៌។

៤) យើងខ្ញុំនៅតែបន្តទទូចស្នើដល់រាជរដ្ឋាភិបាល សូមឱផ្តល់សច្ចាប័នលើអនុសញ្ញារបស់អង្គការពលកម្មអន្តរជាតិខាងផ្នែកការងារ លេខ ១៩០ ស្តីពី « ការលុបបំបាត់អំពើហិង្សា និងការបៀតបៀនក្នុងពិភពការងារ » និងផ្តល់និយមន័យអោយច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយ និងផ្តល់ការដោះស្រាយសម្រាប់គ្រប់ទម្រង់នៃការបៀតបៀន។

៥) យើងខ្ញុំបន្តសំណូមពរដល់រាជរដ្ឋាភិបាល សូមបណ្តុះបណ្តាលដល់ភ្នាក់ងារសន្តិសុខទាំងអស់ដែលគាំទ្រដោយរដ្ឋ ឬរដ្ឋបាលរាជធានី ខេត្ត រួមមានអ្នកគ្រប់គ្រង និងអ្នកចាត់ចែងផ្ទាល់របស់ពួកគេអំពីរបៀបនៃការប្រាស្រ័យទាក់ទងជាមួយសាធារណៈជន និងជាពិសេសស្រ្តីក្រុមអ្នកតវ៉ា និងសហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរ នៃក្រុមហ៊ុនណាហ្គាវើលដ៍ តាមបែបអហិង្សា និងប្រកបដោយឥរិយាបថគិតគូរអំពីយេនឌ័រ និងអោយបុគ្គលដែលរងការចោទប្រកាន់ពីបទប្រព្រឹត្តអំពើហិង្សា និងបៀតបៀនទទួល ខុសត្រូវចំពោះទង្វើរបស់ពួកគេ ។

៦) យើងខ្ញុំសំណូមពរដល់រាជរដ្ឋាភិបាល សូមឱផ្តល់ធនធានថវិកាជាតិដើម្បីធានាថាស្រ្តី និងបុគ្គលអ្នកដែលមិនកំណត់អត្តសញ្ញាណយេនឌ័រទទួលបានការថែទាំសុខភាពផ្លូវភេទ និងសុខភាពបន្តពូជបានត្រឹមត្រូវ រួមមានការថែទាំសុខភាពមុនពេលសម្រាល និងយុទ្ធនាការចាក់វ៉ាក់សាំងដល់ស្រ្តីមានផ្ទៃពោះទាំងអស់ដើម្បីកាត់បន្ថយអត្រាមរណភាពមាតា និងទារក។

# ការវិវឌ្ឍន៍នៃការអនុវត្តនូវសេចក្តីសង្កេតសន្និដ្ឋានអនុសញ្ញាស៊ីដ ឆ្នាំ២០១៩

**សំគាល់**

ពណ៌ក្រហម = មានការវិឌ្ឍន៍តិចតួច ឬមិនមានសោះ ពណ៌លឿង=មានការរីកម្រើនខ្លះ ពណ៌បៃតង=មានការរីកចម្រើនគួរឱ្យកត់សម្គាល់

| លេខរៀងកថាខណ្ឌនៃសេចក្តីសង្កេតសន្និដ្ឋានអនុសញ្ញាស៊ីដ | ប្រធានបទ | សេចក្តីសង្ខេប | ២០២០ កម្រិត | ការវិវឌ្ឍន៍ឆ្នាំ២០២១ | ២០២១ កម្រិត |
|---|---|---|---|---|---|
| ៦ | SDGs | ទទួលស្គាល់ស្ត្រីជាកំលាំងចលករនៃការអភិវឌ្ឍន៍ប្រកបដោយស្មេរភាព | (បៃតង) | បានអនុវត្តរួចហើយ | (បៃតង) |
| ៩ក | ក្របខណ្ឌច្បាប់ | និយមន័យនៃការរើសអើងនៅក្នុងច្បាប់ | (ក្រហម) | មិនទាន់បានអនុវត្តនៅឡើយ | (ក្រហម) |
| ៩ខ | ក្របខណ្ឌច្បាប់ | ការសិក្សាវាយតម្លៃពីច្បាប់ដែលមានឥទ្ធពលលើយ៉េនឌ័រជាលក្ខណៈប្រព័ន្ធ | (ក្រហម) | មិនទាន់បានអនុវត្តនៅឡើយ | (ក្រហម) |
| ១១ក | ការទទួលបានយុត្តិធម៌ | ជំនួយផ្នែកច្បាប់ដោយមានការផ្តល់ថវិកាជំនួយពីរដ្ឋក្នុងរយៈពេលវែងសាលាឧទ្ធរណ៍តាមតំបន់ | (លឿង) | បានអនុវត្តផ្នែកខ្លះ ក្នុងនោះ មានការផ្តល់ថវិកាបន្ថែមលើជំនួយផ្នែកច្បាប់ ប៉ុន្តែមិនទាន់គ្រប់គ្រាន់ និងមិនមានរយៈពេលវែង។ ពុំមានសាលាឧទ្ធណ៍ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០២១ នេះឡើយ។ | (លឿង) |
| ១១ខ | ការទទួលបានយុត្តិធម៌ | បញ្ចប់ការទទួលរងស្លាកស្នាមមិនល្អក្នុងការរាយការណ៍ពីការលោភបំពានសិទ្ធិ | (លឿង) | រដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ បន្តអនុវត្តយុទ្ធនាការដើម្បីជំរុញលើកទឹកចិត្តឱ្យធ្វើការរាយការណ៍ពីករណីនៃអំពើហិង្សាផ្អែកលើយេនឌ័រ ប៉ុន្តែពុំទាន់មានការគាំទ្រដើម្បីឱ្យធ្វើការរាយការណ៍ពីអំពើហិង្សាដែលគាំទ្រដោយរដ្ឋនោះទេ។ | (លឿង) |

| | | | | | |
|---|---|---|---|---|---|
| ១១គ | ការទទួលបានយុត្តិធម៌ | ផ្សព្វផ្សាយព័ត៌មានអំពីដំណោះស្រាយ | | ក្រសួងកិច្ចការនារី បានជួយធ្វើការផ្សព្វផ្សាយព័ត៌មានមួយចំនួនអំពីកម្រិតនៃសេវាដែលអាចរកបាន ប៉ុន្តែមានការជួយតិចតួចក្នុងការទទួលបានដំណោះស្រាយតាមផ្លូវច្បាប់ប្រកបដោយប្រសិទ្ធភាព។ | |
| ១១ឃ | ការទទួលបានយុត្តិធម៌ | ប្រព័ន្ធយុត្តិធម៌ដែលគិតគូពីយេនឌ័រ មានស្ត្រីកាន់តែច្រើនទទួលបានវគ្គបណ្តុះបណ្តាលអំពីអនុសញ្ញាស៊ីដ | | ការបណ្តុះបណ្តាលអំពីគោលការណ៍ថ្មីស្តីពីកម្រិតនៃការប្រើប្រាស់ការសម្រុះសម្រួលដើម្បីជាការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី កំពុងត្រូវបានដាក់ឱ្យសាកល្បង និងមានការបណ្តុះបណ្តាលអំពីអនុសញ្ញាស៊ី-ដរ។ ទោះយ៉ាងនេះក្តី នៅមានកិច្ចការជាច្រើនថែមទៀត ត្រូវការអនុវត្ត ដើម្បីធ្វើឱ្យប្រព័ន្ធយុត្តិធម៌មានលក្ខណៈគិតគូពីយេនឌ័រ។ | |
| ១១ង | ការទទួលបានយុត្តិធម៌ | ការស៊ើបអង្កេត និងការដាក់ទោសលើករណីនៃអំពើហិង្សាក្នុងគ្រួសារ និងការរំលោភសេពសន្ថវៈ ត្រូវមានលក្ខណៈ មិនលំអៀង ឯករាជ្យ និងតាមផ្លូវតុលាការ | | ពុំមានការរីកចម្រើននៅឡើយ។ ប្រព័ន្ធយុត្តិធម៌ នៅមានលក្ខណៈលំអៀង ឬមិនឯករាជ្យនៅឡើយ។ ករណីនៃអំពើហិង្សាក្នុងគ្រួសារ និងការរំលោភសេពសន្ថវៈ មិនត្រូវបានធ្វើការស៊ើបអង្កេតជាប្រចាំ និងជារឿយៗនៅតែមាននិទ្ទណ្ឌភាព។ | |
| ១១ច | ការទទួលបានយុត្តិធម៌ | ឱ្យមន្ត្រីដែលជាប់ពាក់ព័ន្ធនឹងអំពើពុករលួយទទួលខុសត្រូវលើទង្វើរបស់ខ្លួន | | មិនទាន់មានការរីកចម្រើននៅឡើយ។ | |

| | | | | | |
|---|---|---|---|---|---|
| ១៣ក | វិវាទ | ភាពត្រឹមត្រូវចំពោះជនរងគ្រោះនៃអំពើហិង្សាផ្អែកលើយេនឌ័រក្នុងសម័យខ្មែរក្រហម | | សាលាក្តីខ្មែរក្រហម (ECCC) បានទម្លាក់ចោលករណីដែលនៅសល់ចុងក្រោយប្រឆាំងនឹងមន្ត្រីខ្មែរក្រហម លោក មាស មុត នៅក្នុងខែធ្នូ ឆ្នាំ២០២១។ សាលាក្តីនេះមិនត្រូវបានរំពឹងថានឹងផ្តល់ភាពត្រឹមត្រូវនៅចំណុចនេះទេ។ | |
| ១៣ខ | វិវាទ | ផែនការសកម្មភាពស្តីពី **SCR 1325** | | ពុំទាន់មានសកម្មភាពនៅឡើយ | |
| ១៣គ | វិវាទ | ស្ត្រីត្រូវចូលរួមក្នុងការកសាងសន្តិភាពនៅគ្រប់ដំណាក់កាលទាំងអស់ | | ពុំទាន់មានការផ្លាស់ប្តូរនៅឡើយ។ កម្ពុជានៅបន្តបញ្ចូលស្ត្រីនៅស្ទើគ្រប់ដំណាក់កាល លើកលែងនៅកម្រិតខ្ពស់បំផុត។ | |
| ១៥ក | យន្តការដឹកនាំថ្នាក់ជាតិ | ស្វ័យភាពសម្រាប់ CNCW | | ពុំទាន់មានការផ្លាស់ប្តូរនៅឡើយរ។ | |
| ១៥ខ | យន្តការដឹកនាំថ្នាក់ជាតិ | ថវិកាជាតិសម្រាប់ការអនុវត្តពេញលេញនូវគោលនយោបាយយ៉េនឌ័រ | | ពុំទាន់មានសកម្មភាពនៅឡើយ។ | |
| ១៥គ | យន្តការដឹកនាំថ្នាក់ជាតិ | ការចូលរួមរបស់អង្គការសង្គមស៊ីវិលនៅក្នុង NPGE | | រាល់សកម្មភាពត្រូវបានផ្អាកនៅក្នុងឆ្នាំ ២០២១ | |
| ១៥ឃ | យន្តការដឹកនាំថ្នាក់ជាតិ | ការត្រួតពិនិត្យ និងការវាយតម្លៃប្រកបដោយប្រសិទ្ធភាពលើគោលនយោបាយនានាសកម្មភាពយ៉េនឌ័រនៅថ្នាក់ក្រសួង | | ក្រសួងមួយចំនួន បានចូលរួមក្នុងសិក្ខាសាលាស្តីពី TWGG-GBV ដើម្បីបង្កើតផែនការសកម្មភាពអំពី NAPVAW3 ប៉ុន្តែការត្រួតពិនិត្យ និងវាយតម្លៃ នៅមានកម្រិតខ្សោយ។ | |
| ១៧ | ស្ថាប័នសិទ្ធិមនុស្ស | បង្កើតឱ្យមានស្ថាប័នសិទ្ធិមនុស្សស្របតាមគោលការណ៍ទីក្រុងប៉ារីសនីយួយៗ (per Paris Principles) | | រដ្ឋាភិបាលកំពុងស្នើឱ្យមាន NGRI មួយ ប៉ុន្តែមិនមានយន្តការដើម្បីធ្វើឱ្យវាស្របតាមគោលការណ៍ទីក្រុងប៉ារីស ។ បរិយាកាសសិទ្ធិមនុស្ស និងនយោបាយនាពេលបច្ចុប្បន្ន អាចនឹងរារាំងស្ថាប័ននានាពីឯករាជ្យភាព និងប្រសិទ្ធិភាព។ | |

| | | | | | |
|---|---|---|---|---|---|
| ១៩ | សង្គមស៊ីវិល | ធានាឱ្យមាននូវសេរីភាពនៃការបញ្ចេញមតិ ការប្រមូលផ្តុំ និងការចូលរួមសមាគម | | មានការថយចុះនៅក្នុងចំណុចនេះ។ ស្ត្រីកម្ពុជា មានសេរីភាពកាន់តែតិចជាងមុនក្នុងឆ្នាំ២០២១។ | |
| ២១ក | វិធានការពិសេសបណ្តោះអាសន្ន | ការបែងចែកដីធ្លីឡើងវិញសម្រាប់ភាពជាម្ចាស់កម្មសិទ្ធិរបស់ស្ត្រីដោយស្មើភាពគ្នា | | មិនទាន់មានកិច្ចប្រឹងប្រែងនៅឡើយ។ | |
| ២១ខ | វិធានការពិសេសបណ្តោះអាសន្ន | ការផ្តល់ទីសុវត្ថិភាពសម្រាប់ស្ត្រី | | វិបត្តិកូវី-១៩ រឹតធ្វើឱ្យស្ថានភាពកាន់តែពិបាកសម្រាប់ស្ត្រី។ | |
| ២១គ | វិធានការពិសេសបណ្តោះអាសន្ន | កែលម្អឱកាសសេដ្ឋកិច្ចដោយមានការកំណត់កូតា | | មិនទាន់មានវិធានការពិសេសបណ្តោះអាសន្ននៅឡើយ។ | |
| ២៣ក | ផ្នត់គំនិត | យុទ្ធសាស្ត្រមានលក្ខណៈគ្រប់ជ្រុងជ្រោយដើម្បីលុបបំបាត់ឥរិយាបថនៃការប្រកាន់ភាពជាបុរស | | មិនមានយុទ្ធសាស្ត្រដែលមាន លក្ខណៈគ្រប់ជ្រុងជ្រោយទេ។ មន្ត្រីជាន់ខ្ពស់ បន្តប្រកាន់ខ្ជាប់នូវឥរិយាបថបែបប្រពៃណីចំពោះក្រមសីលធម៌របស់ស្ត្រី។ | |
| ២៣ខ | ផ្នត់គំនិត | វិធីសាស្ត្រផ្សេងៗក្នុងការអប់រំយ៉េនឌ័រ ដោយមិនមានច្បាប់ស្រី | | មិនមានកិច្ចប្រឹងប្រែងទេ។ ហើយមានការធ្លាក់ចុះទៅវិញ ដោយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានស្នើឱ្យមានការបង្កើតក្រមសីលធម៌ផ្លូវការមួយ ដែលក្រមនេះនឹងពង្រឹងផ្នត់គំនិតដែលមានក្នុងច្បាប់ស្រី ឡើងវិញ ។ | |

| | | | | | |
|---|---|---|---|---|---|
| ២៣គ | ផ្ដត់គំនិត | ជំរុញឱ្យមានឥរិយាបថដែលមានលក្ខណៈវិជ្ជមានចំពោះសមភាពយេនឌ័រក្នុងចំណោមយុវវ័យ | | រដ្ឋាភិបាល បន្តចូលរួមក្នុងយុទ្ធនាការប្រព័ន្ធផ្សព្វផ្សាយសង្គម ដែលជំរុញឱ្យមានសមភាពក្នុងបរិបទមួយចំនួន។ | |
| ២៥ក | អំពើហិង្សាផ្អែកលើយេនឌ័រ | ធ្វើការវាយតម្លៃពីផលប៉ះពាល់នៃវិធានការ និងដោះស្រាយឫសគល់នៃបញ្ហា | | ពុំមានកិច្ចប្រឹងប្រែងថ្មីទេ។ ការត្រួតពិនិត្យមួយចំនួនកំពុងត្រូវបានធ្វើឡើងលើការអនុវត្ត NAPVAW3 ដើម្បីវាស់វែងលើលទ្ធផល។ ទោះជាយ៉ាងនេះក្ដី កិច្ចប្រឹងប្រែងភាគច្រើន មិនបានដោះស្រាយឫសគល់នៃបញ្ហានោះទេ។ | |
| ២៥ខ | អំពើហិង្សាផ្អែកលើយេនឌ័រ | ធ្វើការពិនិត្យឡើងវិញឱ្យបានគ្រប់ជ្រុងជ្រោយនូវច្បាប់ស្ដីពីអំពើហិង្សាក្នុងគ្រួសារ ធ្វើវិសោធនកម្មដើម្បីដាក់ទោសទណ្ឌលើរាល់អំពើហិង្សាក្នុងគ្រួសារ សម្របសម្រួលឱ្យមានដីកាការពារ ដំណោះស្រាយប្រកបដោយប្រសិទ្ធភាព | | ពុំមានសកម្មភាពក្នុងឆ្នាំ ២០២១ លើការធ្វើវិសោធនកម្មនៃច្បាប់ស្ដីពីអំពើហិង្សាក្នុងគ្រួសារទេ។ មានផែនការមួយ ដែលគ្រោងនឹងបង្កើតផែនការមួយទៀតនៅក្នុងឆ្នាំ ២០២២ ឬឆ្នាំ២០២៣។ | |
| ២៥គ | អំពើហិង្សាផ្អែកលើយេនឌ័រ | កែលម្អសេវាសំខាន់នានា | | ការអនុវត្តNAPVAW3 បានជួយបង្កើនសមត្ថភាពមួយចំនួនក្នុងការផ្តល់សេវានានា ប៉ុន្តែកង្វះខាតនៃការផ្តល់ថវិកាជំនួយ និងការរឹតបន្តឹងដោយវិបត្តិកូវីដ-១៩ បានធ្វើឱ្យមនុស្សជាច្រើនមិនអាចទទួលបានសេវាផ្សេងៗនោះទេ។ | |

| | | | | | |
|---|---|---|---|---|---|
| ២៥ឃ | អំពើហិង្សាផ្អែកលើយេនឌ័រ | ធ្វើការប្រមូលទិន្នន័យដោយប្រព័ន្ធគ្រប់គ្រងអំពីអំពើហិង្សាផ្អែកលើយេនឌ័រ | | ពុំទាន់មានការកែលម្អនៅឡើយ។ | |
| ២៧ក | ការជួញដូរមនុស្ស | ធ្វើការដោះស្រាយបញ្ហាជាឫសគល់នៃកង្វះខាតនូវឱកាសសេដ្ឋកិច្ច | | ពុំទាន់មានការរីកចម្រើននៅឡើយ។ | |
| ២៧ខ | ការជួញដូរមនុស្ស | ធ្វើការកែលម្អនៃការកំណត់អត្តសញ្ញាណ និងការណែនាំឱ្យទៅរកស្ថាប័នដែលផ្តល់ជំនួយសម្រាប់ជនរងគ្រោះ | | ការរីកចម្រើននៅមានកម្រិតនៅឡើយ។ ភ្នាក់ងាររដ្ឋាភិបាល បន្តចូលរួមក្នុងការផ្តល់សេវាពហុវិស័យសម្រាប់អ្នកនៅរស់រានមានជីវិតពីអំពើហិង្សា ប៉ុន្តែពឹងផ្អែកយ៉ាងខ្លាំងលើអង្គការមិនមែនរដ្ឋាភិបាល និងម្ចាស់ជំនួយពីខាងក្រៅ និងចាំបាច់ត្រូវធ្វើឱ្យមានការរីកចម្រើនបន្ថែមទៀត។ | |
| ២៧គ | ការជួញដូរមនុស្ស | ការដាក់បញ្ចូលជនរងគ្រោះឱ្យរួមរស់នៅក្នុងសង្គមឡើងវិញ | | ការរីចម្រើននៅមានកម្រិតនៅឡើយ។ រដ្ឋាភិបាល ពឹងផ្អែកយ៉ាងខ្លាំងលើអង្គការមិនមែនរដ្ឋាភិបាល និងម្ចាស់ជំនួយពីខាងក្រៅ និងចាំបាច់ត្រូវធ្វើឱ្យមានការរីកចម្រើនបន្ថែម។ | |
| ២៧ឃ | ការជួញដូរមនុស្ស | ការពារស្ត្រីពីការខាតបង់ ការការពារសាក្សី | | ពុំមានការវិវឌ្ឍន៍ថ្មីទេ។ គោលនយោបាយមួយចំនួនបានចូលជាធរមាន ប៉ុន្តែមិនទាន់ត្រូវបានអនុវត្តឱ្យបានពេញលេញ។ | |
| ២៧ង | ការជួញដូរមនុស្ស | ការដាក់ទោសទណ្ឌលើអ្នកប្រព្រឹត្តអំពើជួញដូរមនុស្ស | | អ្នកប្រព្រឹត្តអំពើជួញដូរមនុស្សមួយចំនួនត្រូវបានចាប់ខ្លួន និងធ្វើការចោទប្រកាន់ ប៉ុន្តែមានអ្នកប្រព្រឹត្តអំពើជួញដូរមនុស្សជាច្រើនទៀត មិនដែលត្រូវបានចាប់ខ្លួន។ | |
| ២៧ច | ការជួញដូរមនុស្ស | កុំប្រើប្រាស់មិនត្រឹមត្រូវនូវច្បាប់ប្រឆាំងនឹងការជួញដូរមនុស្សលើអ្នកមិនមែនជាអ្នកប្រព្រឹត្តអំពើជួញដូរ | | ដោយផ្អែកតាមច្បាប់នេះ ស្ត្រីមួយចំនួនត្រូវបានឃុំខ្លួននៅក្នុងឆ្នាំ២០២១ សម្រាប់ការបង្ហាញភាពជាខ្លួនឯងនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម។ | |

| | | | | | |
|---|---|---|---|---|---|
| ២៩ក | អំពើពេស្យាចារ | ធ្វើការពិនិត្យឡើងវិញនូវច្បាប់ដើម្បីមិនធ្វើឱ្យការប្រកបរបរផ្លូវភេទត្រូវជាប់ទោសទណ្ឌ | | ពុំទាន់មានកិច្ចប្រឹងប្រែងនៅឡើយទេ។ | |
| ២៩ខ | អំពើពេស្យាចារ | ដាក់ទោសអ្នកកេងប្រវ័ញ្ចលើអំពើនេះ | | មានកិច្ចប្រឹងប្រែងមួយចំនួន។ មានករណីមួយចំនួនត្រូវបានយកមកផ្តន្ទាទោស ប៉ុន្តែនៅមានអ្នកកេងប្រវ័ញ្ចជាច្រើនទៀត នៅមិនទាន់ទទួលការដាក់ទោស។ | |
| ២៩គ | អំពើពេស្យាចារ | ដោះស្រាយបញ្ហាជាឫស គល់ ដូចជាភាពក្រីក្រ តម្រូវការវិសមភាព | | ពុំទាន់មានកិច្ចប្រឹងប្រែងថ្មីនៅឡើយ។ | |
| ២៩ឃ | អំពើពេស្យាចារ | ផ្តល់នីតិសម្បទា | | ពុំទាន់មានកិច្ចប្រឹងប្រែងថ្មីនៅឡើយ។ | |
| ៣១ក | ជីវិតសាសាធារណៈ | អនុម័តវិធានការពិសេសបណ្តោះអាសន្ន ដូចជាការ ផ្តល់កូតា | | ពុំទាន់មានកិច្ចប្រឹងប្រែងនៅឡើយ។ | |
| ៣១ខ | ជីវិតសាធារណៈ | បង្កើតបរិយាកាសដែលជួយដល់ស្ត្រី | | ពុំទាន់មានកិច្ចប្រឹងប្រែងនៅឡើយ។ | |
| ៣៣ក | សញ្ជាតិ | ការទទួលបានសញ្ជាតិ ការអប់រំ ការងារ ការថែទាំសុខភាព ផ្តល់ជម្រកដល់ស្ត្រីដែលមានសញ្ជាតិជាជនជាតិវៀតណាម និងមានដើមកំណើតខ្មែរ | | ពុំទាន់មានកិច្ចប្រឹងប្រែងនៅឡើយ។ | |

| | | | | | |
|---|---|---|---|---|---|
| ៣៣ខ | សញ្ជាតិ | សម្របសម្រួលដល់ការធ្វើឯកសារកំណត់អត្តសញ្ញាណ និងសំបុត្រកំណើតដោយគ្មានការដកហូតឯកសារ | | ពុំទាន់មានកិច្ចប្រឹងប្រែងថ្មីនៅឡើយ។ | |
| ៣៣គ | សញ្ជាតិ | ផ្តល់សច្ចាប័នលើអនុសញ្ញាចំនួនពីរស្តីពីភាពមិនមែនជាពលរដ្ឋនៃប្រទេសណាមួយ (Statelessness) | | ពុំទាន់មានការរីកចម្រើននៅឡើយ។ | |

| | | | | | |
|---|---|---|---|---|---|
| ៣៥ក | ការអប់រំ | បង្កើនការទទួលបានការអប់រំនៅកម្រិតអនុវិទ្យាល័យ លុបបំបាត់កត្តារារាំងសម្រាប់កុមារី | | ផែនការយុទ្ធសាស្ត្រស្តីពី ការបញ្ជ្រាបយេនឌ័រនៅក្នុងការអប់រំ ឆ្នាំ២០២១-២០២៥ ត្រូវបានអនុម័តក្នុងឆ្នាំ ២០២១។ ការបិទសាលា និងកង្វះខាតនៃការទទួលបានអ៊ិនធឺណិតគ្រប់គ្រាន់ បានប៉ះពាល់ដល់កុមារី | |
| ៣៥ ខ | ការអប់រំ | ជំរុញលើកទឹកចិត្តដល់កុមារីឱ្យចូលក្នុងវិធីសាស្ត្រអប់រំ STEAM (មុខវិជ្ជាវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្បៈ និងគណិតវិទ្យា) | | កម្មវិធីមួយចំនួន ត្រូវបានអនុម័តដើម្បីជំរុញលើកទឹកចិត្តកុមារីឱ្យសិក្សាមុខវិជ្ជា STEAM។<br>នេះជាផ្នែកមួយនៃការអនុវត្តផែនការបញ្ជ្រាបយេនឌ័រ។ | |
| ៣៥ គ | ការអប់រំ | ផ្តល់វគ្គបណ្តុះបណ្តាលអំពីយ៉េនឌ័រដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយដល់គ្រូបង្រៀន | | ផែនការយុទ្ធសាស្ត្រស្តីពីការបញ្ជ្រាបយេនឌ័រនៅក្នុងការអប់រំ ឆ្នាំ២០២១-២០២៥ បានដាក់បញ្ចូលអនុ<br>សាសន៍របស់គណៈកម្មាធិការស៊ីដ និងដាក់បញ្ចូលវគ្គបណ្តុះបណ្តាលសម្រាប់គ្រូបង្រៀន នៅក្នុងសកម្មភាព។ | |
| ៣៧ ក | ការងារ | បុគ្គលិកកម្មករស្ថិតក្នុងកិច្ចសន្យាមានថេរវេលាកំណត់ ទទួលបានសេរីភាពបង្កើតសហជីព និងអត្ថប្រយោជន៍នៃការឈប់លំហែមាតុភាព<br>restore AC 2-year cap on FDCs | | ពុំទាន់មានកិច្ចប្រឹងប្រែងនៅឡើយ។ ជាក់ស្តែង នយោជកជាច្រើន អនុវត្តគោលការណ៍នៃកិច្ចសន្យាមានថេរវេលាកំណត់ បូក ២ឆ្នាំបន្ថែម។ | |
| ៣៧ ខ | ការងារ | ការពារវិស័យក្រៅប្រព័ន្ធ មានដូចជា អ្នកបម្រើការងារតាមផ្ទះនៅក្នុងច្បាប់ស្តីពីការងារ | | ពុំមានកិច្ចប្រឹងប្រែងគួរឱ្យកត់សម្គាល់ឡើយ។ របបសន្តិសុខសង្គម NSSF បានធ្វើការអំពាវនាវដល់នយោជកនៃអ្នកធ្វើការងារតាមផ្ទះឱ្យផ្តល់របបសន្តិសុខសង្គម។ | |
| ៣៧ គ | ការងារ | ជំរុញលើកទឹកចិត្តឱ្យមានការចែករំលែកតួនាទីជាឪពុកម្តាយ ដោយមានការឈប់លំហែបិតុភាព | | ពុំទាន់មានកិច្ចប្រឹងប្រែងថ្មីនៅឡើយ។ | |

| | | | | | |
|---|---|---|---|---|---|
| ៣៧ ឃ | ការងារ | ការតាក់តែងច្បាប់ដោយមានលក្ខណៈគ្រប់ជ្រុងជ្រោយស្តីពីការបៀតបៀនផ្លូវភេទ ដោយមានដំណោះស្រាយ | | ពុំទាន់មានកិច្ចប្រឹងប្រែងថ្មីនៅឡើយ។ | |
| ៣៧ ង | ការងារ | ធានាឱ្យមានប្រាក់ឈ្នួលស្មើគ្នាសម្រាប់ការងារមានតម្លៃស្មើគ្នា យោងតាមអនុសញ្ញាលេខ ១០០ នៃអង្គការអន្តរជាតិខាងផ្នែកការងារ (ILO C100) | | ពុំមានកិច្ចប្រឹងប្រែងក្នុងការប្រៀបធៀបប្រភេទការងារខុសៗគ្នាដោយមានតម្លៃស្មើគ្នានោះឡើយ។ មិនមានការអនុវត្តជាប្រចាំនូវច្បាប់ដែលមានស្រាប់ស្តីពីប្រាក់ឈ្នួលស្មើគ្នាសម្រាប់ការងារដូចគ្នា។ | |
| ៣៧ ច | ការងារ | ការពារកម្មករចំណាកស្រុកទៅក្រៅប្រទេស | | ពុំមានកិច្ចប្រឹងប្រែងដែលគួរឱ្យកត់សម្គាល់នោះទេ។ មានកិច្ចពិភាក្សាមួយចំនួនអំពីផលប៉ះពាល់លើពលករចំណាកស្រុកនៅពេលបិទព្រំដែន និងការរឹតបន្តឹងអំឡុងពេលវិបត្តិកូវីដ-១៩ ព្រមទាំងមានការដោះស្រាយទៅតាមករណី។ | |
| ៣៧ ឆ | ការងារ | ផ្តល់សច្ចាប័នលើអនុសញ្ញានៃអង្គការអន្តរជាតិខាងផ្នែកការងារ លេខ ១៨៣ លេខ ១៨៩ លេខ ១៩០ | | ពុំទាន់មានកិច្ចប្រឹងប្រែងនៅឡើយទេ។ | |
| ៣៩ ក | សុខភាព | ការទទួលបានជាសកលនូវសេវាថែទាំសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ | | កិច្ចពិគ្រោះយោបល់នានាស្តីពីការពង្រីកផែនការសកម្មភាពជាតិ ត្រូវបានធ្វើឡើងក្នុងឆ្នាំ២០២១។ ប៉ុន្តែការផ្តល់សេវាជាក់ស្តែងនានា ត្រូវបានរាំងស្ទះនៅអំឡុងពេលបិទខ្ទប់។ | |
| ៣៩ ខ | សុខភាព | ការប្រយុទ្ធប្រឆាំងនឹងការទទួលរងស្លាកស្នាមមិនល្អនៃការយកកូនចេញ និងការប្រើប្រាស់វិធីពន្យារកំណើត | | មានធាតុចូលចំពោះការបញ្ចូលនៅក្នុង ក្នុងផែនការសកម្មភាពជាតិ ប៉ុន្តែពុំមានសកម្មភាពណាត្រូវបានអនុវត្តនៅឡើយ។ | |
| ៣៩ គ | សុខភាព | ដោះស្រាយតម្រូវការអាហារូបត្ថម្ភរបស់ស្ត្រីនៅក្នុងយុទ្ធសាស្ត្រនានា | | ពុំទាន់មានការប្រែប្រួលនៅឡើយទេ។ | |

| | | | | | |
|---|---|---|---|---|---|
| ៣៩ ឃ | សុខភាព | ការទប់ស្កាត់មហារីកស្បូន | | មានធាតុចូលចំពោះការបញ្ចូលនៅក្នុង ក្នុងផែនការសកម្មភាពជាតិ ប៉ុន្តែពុំមានសកម្មភាពណាត្រូវបានអនុវត្តនៅឡើយ។ | |
| ៤១ | ស្ត្រីជនបទ | ធ្វើនិយតកម្មលើគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងកែលម្អការទទួលបានប្រាក់កម្ចីដែលមានអត្រាការប្រាក់ទាប ជួយគាំទ្រដល់អាជីពខ្នាតធំដែលមានស្ត្រីជាម្ចាស់ | | វិស័យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ មិនត្រូវបានធ្វើនិយតកម្មប្រកបដោយប្រសិទ្ធភាព ដូចជា អ្នកខ្ចីប្រាក់ ត្រូវទទួលរងកម្ចីដែលមានការប្រាក់ខ្ពស់ និងដំណើរការប្រមូលប្រាក់ដែលនាំឱ្យជំពាក់បំណុលច្រើន ការលក់ដីដោយបង្ខំ ពលកម្មកុមារ អសុន្តិសុខផ្នែកចំណីអាហារ ការធ្វើចំណាកស្រុកដែលបណ្តាលមកពីការជំពាក់បំណុល និងផលប៉ះពាល់ផ្សេងទៀត។[31] | |
| ៤៣ ក | ការប្រែប្រួលអាកាសធាតុ | បញ្ចូលស្ត្រីក្នុងការបង្កើតគោលនយោបាយ | | ការដាក់បញ្ចូលសម្លេងរបស់ស្ត្រីនៅមានកម្រិតក្នុងការបង្កើតគោនយោបាយ ប៉ុន្តែពុំមានការវិភាគលើយេនឌ័រដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ត្រូវបានយកមកអនុវត្តនៅឡើយ។ | |
| ៤៣ ខ | ការប្រែប្រួលអាកាសធាតុ | បញ្ចូលទស្សនៈវិស័យយេនឌ័រដែលមានលក្ខណៈច្បាស់លាស់ទៅក្នុងគោលនយោបាយ | | ការបញ្ជ្រាបយេនឌ័រនៅក្នុងផែនការសកម្មភាពជាតិស្តីពីការប្រែប្រួលអាកាសធាតុ ត្រូវបានបង្កើតឡើង។ | |
| ៤៥ ក | ស្ត្រីស្ថិតក្នុងការឃុំខ្លួន | ប្រើវិធីសាស្ត្រផ្សេងទៀតជំនួសដោយការឃុំខ្លួន | | មិនទាន់មានការរីកចម្រើននៅឡើយ។ វិធានការផ្សេងទៀតជំនួសដោយការឃុំខ្លួន ដូចជា ការដោះលែងមុនការជំនុំជំរះក្តី និងការប្រើប្រាស់ការព្យួរទោស មិនត្រូវបានពិចារណា និងអនុវត្តឱ្យបានសមស្រប ដូចជា ចំពោះស្ត្រីមានផ្ទៃពោះ និងស្ត្រីដែលមានកូនតូចនៅជាមួយនោះទេ។ | |
| ៤៥ ខ | ស្ត្រីស្ថិតក្នុងការឃុំខ្លួន | ដោះស្រាយបញ្ហាជាឬសគល និងផលប៉ះពាល់លើកុមារពីការកាត់ឱ្យជាប់ពន្ធនាគារ | | មិនទាន់មានការរីកចម្រើនទេ។ | |
| ៤៥ ឃ | ស្ត្រីស្ថិតក្នុងការឃុំខ្លួន | កាត់បន្ថយចំនួនមនុស្សលើសចំណុះ សេវា តាម | | មិនទាន់មានការរីកចម្រើននៅឡើយទេ។ បើទោះជាមានហានិភ័យបន្ថែមដោយសារ | |

[31] https://www.licadho-cambodia.org/articles/20210628/173/index.html

| | | | | | |
|---|---|---|---|---|---|
| | | វិធានទីក្រុងបាំងកក និង វិធានណេលសាន់ ម៉ានដេឡា (per Bangkok rules and Nelson Mandela rules) | | វិបត្តិនៃជំងឺកូវីដ-១៩ក៏ដោយ ក៏ពន្ធនាគារនៅបន្តដាក់ចំនួនមនុស្សលើសឆ្ងាយពីអត្រាចំណុះផ្លូវការរបស់ខ្លួន និងមិនធានានូវការទទួលបានសេវាចាំបាច់នានាដែរ។ | |
| ៩៧ ក | ស្ត្រីពរពោះជំនួស | លុបចោលសេចក្តីសម្រេចក្នុងខែធ្នូ ឆ្នាំ២០១៦ ដើម្បីអនុញ្ញាតឱ្យស្ត្រីពរពោះជំនួសមានសិទ្ធិចិញ្ចឹមក្មេងក្នុងនាមជាកូនបង្កើតរបស់ខ្លួន | | មិនមានផែនការកែប្រែសេចក្តីសម្រេចនេះនៅឡើយទេ។ ជាក់ស្តែង ស្ត្រីត្រូវបានកាត់ទោសដោយតុលាការចំពោះការធ្វើជាអ្នកពរពោះជំនួស។ | |
| ៩៧ ខ | ស្ត្រីពរពោះជំនួស | ដោះស្រាយបញ្ហាជាឬសគល់ ដោយកែលម្អឱកាសនៃការរកប្រាក់ចំណូល | | មិនទាន់មានសកម្មភាពទេ។ | |
| ៩៧ គ | ស្ត្រីពរពោះជំនួស | ធានាថា ច្បាប់ និងគោលនយោបាយ នឹងជួយដោះស្រាយអតុល្យភាពអំណាចនៃស្ត្រីពរពោះជំនួស | | មិនទាន់មានកិច្ចប្រឹងប្រែងនៅឡើយ។ | |
| ៩៧ ឃ | ស្ត្រីពរពោះជំនួស | ច្បាប់មិនគួរដាក់ទោសទណ្ឌលើស្ត្រីពរពោះជំនួស | | មិនទាន់មានមានសកម្មភាពជាវិជ្ជមាននៅឡើយ។ ស្ត្រីពរពោះជំនួស ត្រូវបានកាត់ឱ្យជាប់ទោសពីបទឧក្រិដ្ឋ ចាប់តាំងពីអនុសាសន៍ទាំងនេះ ត្រូវបានធ្វើឡើងម្លេះ។ | |
| ៩៩ ក | អាពាហ៍ពិពាហ៍ | វិធានការនានា ផ្តោលើការបន្ថយអត្រានៃការរៀបអាពាហ៍ពិពាហ៍កុមារ | | មិនទាន់មានសកម្មភាពគួរឱ្យកត់សម្គាល់នៅឡើយទេ។ មានក្តីកង្វល់ថា វិបត្តិកូវីដ-១៩ បានជំរុញឱ្យអត្រានៃការរៀបអាពាហ៍ពិពាហ៍កុមារកើនឡើងនៅតាមទីជនបទ។[32] | |
| ៩៩ ខ | អាពាហ៍ពិពាហ៍ | លុបចោលមាត្រា ៩៥០ នៃក្រមរដ្ឋប្បវេណី | | មិនមានកិច្ចប្រឹងប្រែងធ្វើឡើងក្នុងការលុបចោលមាត្រានេះទេ។ | |

[32] https://cambojanews.com/experts-fear-child-marriage-on-the-rise-in-ratanakiri-and-mondulkiri-amid-covid-19-pandemic/